ស.ប.ស.ខ

សមាគមបុគ្គលិកសិក

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

* ចំណងមិត្តភាពនិងការឧបត្ថម្ភគ្នាទៅវិញទៅមក
* ការពង្រឹងនិងពង្រីកចំណេះដឹង និង វិជ្ជាជីវៈ
* ការការពារផលប្រយោជន៍គ្នាទាំងផ្លូវចិត្ត - សម្ភារៈ

៥៧

# ទស្សនាវដ្តី គ្រូបង្រៀន



ផ្ទះគ្រូបង្រៀន ខេត្តកំពត ចាប់ដំណើរការ

ត្រីមាសទី៣ ឆ្នាំ២០១៩

ផ្សាយចេញរាល់ត្រីមាសពីទីចាត់ការសមាគមបុគ្គលិកសិក្សាខ្មែរ

១២៨B មហាវិថីព្រះនរោត្តម (ភ្នំពេញ)

ទូរស័ព្ទ : ០២៣ ២១៦ ១៨៤_០១៧ ៤៨៨ ៨៧៦

Facebook: kta amcek

# មាតិកា


| ល.រ | ចំណងជើងអត្ថបទ | ទំព័រ |
|---|---|---|
| ១ | វិចារណកថា | ១ |
| | **វប្បធម៌ទូទៅ** | |
| ២ | ប្រភពនៃការអប់រំក្នុងពិភពលោក (ត) | ៣ |
| ៣ | ព្រះភក្ត្រព្រះព្រហ្មតំណាងដោយបាយ័នមុខ៤មែនឬទេ ? | ៥ |
| ៤ | ប្រវត្តិនៃជនជាតិជ្វីហ្វ (អ៊ីស្រាអែល) | ៧ |
| ៥ | ទេវកថា កូរសមុទ្រទឹកដោះ (តចប់) | ១០ |
| ៦ | រឿងទាក់ដំរី (ត) | ១៣ |
| | **ចិត្តវិទ្យាអប់រំ** | |
| ៧ | គ្រូបង្រៀនជាអ្នកសម្របសម្រួលគឺមិនមែនបង្ខំសិស្សឲ្យធ្វើតាមខ្លួនទាំងស្រុងឡើយ | ១៥ |
| ៨ | ចរិតកុមារ | ១៧ |
| | **ការអប់រំ និងគរុកោសល្យ** | |
| ៩ | អំពីសិលាចារឹកនៃប្រទេសកម្ពុជា (ត) | ២០ |
| ១០ | អត្ថប្រយោជន៍នៃទិវាអំណានកម្ពុជា (ត) | ២៣ |
| ១១ | អំពីនិបាតស័ព្ទ និងអាយតនិបាត(ត) | ២៥ |
| | **កំណាព្យ និងកម្សាន្ត** | |
| ១២ | បណ្តាំឪពុក | ២៧ |
| ១៣ | កំហុសអ្នកណា ? (ត) | ២៩ |
| | **វេទិកាស្វែរិន** | |
| ១៤ | ចរិតខ្មែរ | ៣១ |
| ១៥ | វិជ្ជាអប់រំកាយ | ៣៤ |
| | **ព័ត៌មាន** | |
| ១៦ | យោបល់និងការពន្យល់ខ្លះៗអំពីតារាងប្រវត្តិកាលនៃអក្សរសាស្ត្រខ្មែរ(ត) | ៣៧ |
| ១៨ | តើហេតុដូចម្តេចបានជាខែកុម្ភៈមានតែ២៨ ឬ២៩ថ្ងៃ | ៤០ |
| ១៩ | ស្ថិតិសពពីខែ ឧសភា ដល់ខែ សីហា ឆ្នាំ២០១៨ | ៤១ |



## គណៈកម្មការរៀបរៀង និង និពន្ធ

- លោក ជ័យ សយ្យនា
- លោក ថោង បូរ៉ាន់
- លោកស្រី គុយ ផល្លា
- លោក ជន ឈាងលី
- លោកស្រី ម៉ក់ ណាង
- លោក វង្ស សុគន្ធ
- លោក លី ហាក់សេង
- លោក អ៊ុម ជា
- សមាជិកសមាជិកា ស. ប. ស.ខ

## គណៈកម្មការត្រួតពិនិត្យ

លោក យស់ អ៊ាង
- លោកស្រី ប្រាក់ សុលីដា
- លោក ព្រុំ សាមិត
- លោក សួង សារុណា
- លោក ស៊ុង វ៉ាន់ថន
- លោក ស៊ិន ស៊ីម
- លោក អ៊ុង តុលា

## ការីកុំព្យូទ័រ

លោកស្រី លី មីស្មៀល

## ក្របខាងក្រៅ

- ពីមុខ : ផ្ទះគ្រូបង្រៀន ខេត្តកំពត ចាប់ដំណើរការ។
- ពីក្រោយ : ពិធីបុណ្យអុំទូកនៅភ្នំពេញ ឆ្នាំ១៩០៩


**<u>លេខទូរស័ព្ទផ្ទះគ្រូបង្រៀន</u>**

| | | | |
|---|---|---|---|
| **ភ្នំពេញ** | : ០១២ ៥៥៩ ៥៨៦<br>០១២ ៤៨៧ ១៣៥ | **កែប** | : ០៩៧ ៨ ៧២១៨៨០ |
| | | **តាកែវ** | : ០៨១ ៤២៩ ៥៩៥ |
| **ព្រះសីហនុ** | : ០១៦ ៥៦៧ ០១១ | **រតនគិរី** | : ០៩៧ ៩០៤២ ៥៨៤ |
| **សៀមរាប** | : ០១២ ៦៧៥ ៦៤០ | **ព្រះវិហារ** | . ០១២ ២១៨២៨១ |
| **កំពង់ចាម** | : ០១១ ៧៤២ ២២៤ | **បាត់ដំបង** | ០១២ ៩៧៧ ១៨៦ |
| **ស្វាយរៀង** | : ០៩៧ ២៦៥៥ ៩៨៧ | **ស្ទឹងត្រែង** | : ០១២ ៩៦៤ ៤៩៦ |
| **ព្រៃវែង** | : ០១២ ៦៧១ ៦៤០ | **កំពត** | : ០១២ ៨៥៦ ៧២២<br>០៩៦ ២៨១ ៩៦៤២ |
| **ប៉ៃលិន** | : ០១៥ ៥៨០ ០១២ | **មណ្ឌលគិរី** | : ០៨៨ ៥៦៥ ១៨៧៩ |

# វិចារណកថា

តើ STEM (ស្ទែម) ជាអ្វី? ជាអក្សរកាត់នៃមុខវិជ្ជា៤គឺ : Scinece វិទ្យាសាស្ត្រ Technology បច្ចេកវិទ្យា Engineering វិស្វកម្ម និង Mathematics គណិតវិទ្យា ដែលចាត់ថ្នាក់ក្នុងផ្នែកវិទ្យាសាស្ត្រពិតរបស់កម្មវិធីសិក្សា នៃប្រព័ន្ធអប់រំកម្ពុជា។

STEMមានគោលដៅអប់រំបណ្ដុះបណ្ដាលសិស្សនៃកម្រិតមធ្យមសិក្សាទុតិយភូមិនិងនិស្សិតនៃកម្រិតឧត្ដមសិក្សា ក្រោយឧត្ដមសិក្សា សិក្សាឯកទេស និងការស្រាវជ្រាវដើម្បីឆ្លើយតបនឹងការរីកចម្រើនរហ័ស របស់វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម ព្រមទាំងផ្ដល់ឱកាសឲ្យទទួលបាន ការងារក្នុងជំនាញច្បាស់លាស់ម្យ៉ាង និងម្យ៉ាងទៀតដើម្បីរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចសង្គមឲ្យកាន់តែរឹងមាំពោលគឺកម្មវិធី STEM នឹងផ្ដល់ជូនលទ្ធផលវិជ្ជមានលើគ្រប់វិស័យ នៃព្រះរាជាណាចក្រកម្ពុជា។

វិធីសាស្ត្រអនុវត្ត STEM នឹងជួយបង្កើនសមត្ថភាពសិស្សនិស្សិតឲ្យកាន់តែខ្ពស់ ក៏ដូចជាជួយសម្របពួកគេទៅនឹងការប្រែប្រួល ការផ្លាស់ប្ដូរដ៏ឆាប់រហ័ស និងការប្រកួតប្រជែងដ៏ខ្លាំងក្លាលើគ្រប់ វិស័យ ដែលទាមទារឲ្យសិស្ស និស្សិតនាបច្ចុប្បន្ននេះត្រូវតែមានជំនាញច្បាស់លាស់ ក្នុងខណៈពេលដែលចំនួនគ្រឹះស្ថានសិក្សា សិស្ស និងនិស្សិតកើនកាន់តែច្រើន។ ដូចនេះសម្ភារឧបទេស គ្រូបង្រៀន សាស្ត្រាចារ្យក៏ត្រូវតែមានសមត្ថភាព អាកប្បកិរិយាល្អ និងឆន្ទៈយកចិត្តទុកដាក់ចំពោះសិស្ស និស្សិត ដើម្បីដឹកនាំបង្រៀន និងអនុវត្តជាលក្ខណៈបរិយាប័ន្ន។ មុខវិជ្ជា STEM មានទំនាក់ទំនងគ្នា ពីមុខវិជ្ជាមួយទៅមុខវិជ្ជាមួយទៀត ដែលទង្វើនេះនាំឲ្យសិស្ស និស្សិតទទួលបានការយល់ដឹងទូលំទូលាយអំពីមុខវិជ្ជានីមួយៗ ពិសេសការប្រើប្រាស់មុខវិជ្ជាក្នុងបរិបទនៃភពផែនដី ដោយពិតប្រាកដ។

អ្វីដែលសំខាន់នៅត្រង់ថា តើកម្មវិធី STEM នេះត្រូវបង្រៀនសិស្ស និស្សិតយ៉ាងដូចម្ដេច? បទពិសោធន៍ប្រកបដោយផ្លែផ្កានៃគ្រឹះស្ថានសិក្សា មួយចំនួនបង្ហាញថា សិស្ស និស្សិត ត្រូវរៀនជាមួយគ្នាជាក្រុមតាមគោលវិធីសិស្សមជ្ឈមណ្ឌលដោយប្រើប្រាស់បច្ចេកវិទ្យា និងសម្ភារៈនៃបន្ទប់ពិសោធន៍យ៉ាងសម្បូរបែបលើផ្នែកទ្រឹស្ដី និងការអនុវត្ត ទាំងក្នុងនិងក្រៅសាលារៀន ពិសេសការធ្វើទស្សនកិច្ចសិក្សា កម្មសិក្សាដកបទពិសោធន៍នៅតាមសហគ្រាសគ្រឹះស្ថានសេដ្ឋកិច្ច ផលិតកម្ម កសិដ្ឋាន ស្របតាមទស្សនៈខុង ជឺថា "ខ្ញុំឮ ហើយខ្ញុំភ្លេច ខ្ញុំមើលឃើញហើយខ្ញុំចាំ ខ្ញុំធ្វើហើយខ្ញុំយល់" ឬទស្សនៈយើងថា "បានឮ ១០០ដង មិនស្មើបានឃើញ១ដង" ។ តាមទស្សនៈទាំងនេះ សិស្ស និស្សិតត្រូវយល់ថា នេះជារបៀបរៀនដែលត្រូវតែមានការអនុវត្តដោយផ្ទាល់។ ប៉ុន្តែគ្រូបង្រៀន សាស្ត្រាចារ្យ ក៏ត្រូវមានឆន្ទៈមុតមាំដែរ ដើម្បីបង្រៀនសិស្ស និស្សិត ដែលប្រការនេះ ជាល័ក្ខខ័ណ្ឌចាំបាច់ និងគ្រប់គ្រាន់មិនអាចខ្វះបាន។

បើការអនុវត្តកម្មវិធី STEM ទទួលផលវិជ្ជមាន មានន័យថា វិទ្យាល័យដឹកនាំសិស្សឲ្យត្រៀមលក្ខណៈបានល្អ នៅពេលពួកគេចូលទៅរៀននៅកម្រិតឧត្ដមសិក្សា។ ដោយឡែកសម្រាប់និស្សិតនារី យើងកំពុងលើកទឹកចិត្តដើម្បីជម្នះការយល់ថា មានតែនិស្សិតប្រុសទេដែលរៀនពូកែក្នុងមុខ

វិជ្ជា STEM។ តែជាក់ស្ដែងការចុះឈ្មោះរបស់និស្សិតនារី ចូលរៀននៅកម្រិតឧត្ដមសិក្សា ផ្នែកវិទ្យាសាស្ដ្រពិត ក៏កើនឡើងគួរឲ្យកត់សម្គាល់ ដោយសារកម្មវិធី STEM នៅកម្រិតវិទ្យាល័យទទួលបានលទ្ធផលល្អ។

ជាសន្និដ្ឋាន រាល់កិច្ចព្រមព្រៀងរវាងសាកលវិទ្យាល័យនៅកម្ពុជា ទាំងផ្នែកសាធារណៈ និងឯកជន និងសាកលវិទ្យាល័យនានា ក្នុងនិងក្រៅតំបន់ សុទ្ធតែជាគំនាស់ជួយលើកគុណភាពអប់រំទៅកម្រិតឧត្ដមសិក្សា ជាពិសេសការស្រាវជ្រាវផ្សេងៗ ដែលញុំាងឲ្យបញ្ញវន្ដយើង អាចផ្លាស់ប្ដូរធាតុប្រផេះ ដោយស្មើភាពជាមួយនឹងបញ្ញវន្ដបរទេសដើម្បីបុព្វហេតុសកលនៃការអប់រំវិទ្យាសាស្ដ្រ និងវប្បធម៌ ឆ្ពោះទៅសម្រេចចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជាគឺកសាងសេដ្ឋកិច្ចឌីស៊ីថល និងអភិវឌ្ឍគោលនយោបាយឧស្សាហកម្មជំនាន់ទី៤៕

គណៈកម្មាធិការកណ្ដាលស.ប.ស.ខ.

## សេចក្ដីកែតម្រូវ

ក្នុងទស្សនាវដ្ដីគ្រូបង្រៀនលេខ ៥៦ មានកំហុសឆ្គងពាក្យ និង អក្ខរាវិរុទ្ធមួយចំនួន។

សូមមិត្តអ្នកអានមេត្តាជួយកែតម្រូវៈ

| ល.រ | ទំព័រ | បន្ទាត់ | ពាក្យខុស | ពាក្យត្រូវ | ផ្សេងៗ |
|---|---|---|---|---|---|
| 1 | 19 | ទី4 | ថៃ ធូន | ថៃថូន | រាប់ពីក្រោម |
| 2 | 21 | ទី8 | ត្រូវគ្រូតរៀនថ្នាក់ | ត្រូវរៀនគ្រូតថ្នាក់ | រាប់ពីលើ |
| 3 | 23 | ទី16 | លក្ខណះ | លក្ខណៈ | រាប់ពីលើ |
| 4 | 24 | ទី6 | ថៃឡង់៕ | ថៃឡង់។ | រាប់ពីលើ |
| 5 | 36 | ទី1 | យើងស្អាត | ផ្ទះយើងស្អាត | រាប់ពីក្រោម |
| 6 | 36 | ទី1 | ស្អាតគ្រប់គ្នាផ្ទះ | ស្អាតគ្រប់គ្នា | រាប់ពីក្រោម |
| 7 | 40 | ទី2 | សូរ្យប័វិត | សូរ្យបវិត | រាប់ពីលើ |



## ប្រភពនៃការអប់រំក្នុងពិភពលោក (ត)

**ខ-សូក្រាត ៤៦៩-៣៩៩ មុនគ.ស. (ក្រិក)**

1. **ការតម្រង់ទិសខាងទស្សនវិជ្ជា**
   អ្នកបំផ្លាញជំនឿសាសនា មានភាពលំអៀងទៅរកឧត្តមគតិនិយមទស្សនវិជ្ជា និង អភិរក្សនិយមនយោបាយ។
2. **ទស្សនៈស្តីអំពីធម្មជាតិមនុស្ស**
   មនុស្សជាតិអាចកំណត់ខ្លួនឯងបានតាមការពិនិត្យទៅលើខ្លួនឯងប្រកបដោយ វិចារណញ្ញាណ។
3. **ទស្សនៈទៅលើការអប់រំ និងកម្មវិធីសិក្សា**
   - ការប្រើប្រាស់ស្វែងរកការសន្ទនា ប្រកបដោយភាពឈ្លាសវៃ ដើម្បីឆ្លើយតបទៅនឹង ការយកចិត្តទុកដាក់របស់មនុស្សជាមូលដ្ឋាន។
   - ការអប់រំគួរតែបណ្តុះឧត្តមភាពខាងសីលធម៌។
4. **ការរួមចំណែក និងឥទ្ធិពល**
   - ការសន្ទនាតាមបែបសូក្រាត ជាវិធីបង្រៀន។
   - គ្រូមានតួនាទីជាគំរូ។

**គ-ប្លាតុង ៤២៧-៣៤៦ មុនគ.ស. (ក្រិក)**

1. **ការតម្រង់ទិសខាងទស្សនវិជ្ជា**
   អ្នកមានឧត្តមគតិផ្នែកទស្សនវិជ្ជា ជាអ្នកអភិរក្សផ្នែកនយោបាយសង្គម។
2. **ទស្សនៈស្តីពីធម្មជាតិមនុស្ស**
   មនុស្សជាតិអាចត្រូវបានគេចាត់ថ្នាក់ទៅតាមមូលដ្ឋាននៃសមត្ថភាពបញ្ញា។
3. **ទស្សនៈទៅលើការអប់រំ និងកម្មវិធីសិក្សា**
   - ការសំណេះសំណាលពីគំនិតដែលមិនទាន់បង្ហាញឲ្យឃើញ។
   - តន្ត្រី កីឡាកាយសម្ព័ន្ធ ធរណីមាត្រសាស្ត្រ តារាសាស្ត្រ បំណិនខាងអក្សរសិល្ប៍ ជាមូលដ្ឋាននៃការអប់រំ។
   - ទស្សនវិជ្ជា សម្រាប់គ្រប់គ្រងវរជននៃអធិរាជខាងទស្សនវិជ្ជា។

4. **ការរួមចំណែក និងឥទ្ធិពល**
   - ការប្រើប្រាស់សាលារៀនទៅតាមប្រភេទសិស្ស យោងទៅតាមសមត្ថភាពបញ្ញា។
   - ការអប់រំត្រូវផ្សារភ្ជាប់ទៅនឹងគោលបំណង(នយោបាយ)ពលរដ្ឋ។

**ឃ-អារីស្តូត ៣៨៤-៣២២ មុនគ.ស. (ក្រិក)**

1. **ការតម្រង់ទិសខាងទស្សនវិជ្ជា**
   - អ្នកមានគំនិតតថៈខាងផ្នែកទស្សនវិជ្ជា។
   - ទស្សនៈនៃសង្គម នយោបាយ និងការអប់រំ ដោយផ្អែកលើតថនិយមក្លាស៊ីក។
2. **ទស្សនៈស្ដីពីធម្មជាតិមនុស្ស**
   មនុស្សជាតិមានអំណាចប្រកបដោយវិចារណញ្ញាណ ដែលគួរតែបង្ហាញផ្លូវចរិយារបស់គេ។
3. **ទស្សនៈទៅលើការអប់រំ និងកម្មវិធីសិក្សា**
   - ការសង្កត់ធ្ងន់ទៅលើខាងវិទ្យាសាស្ត្រ និងជាសត្យានុម័ត។
   - បំណិនខាងអក្សរសាស្ត្រជាមូលដ្ឋាន គណិតវិទ្យា វិទ្យាសាស្ត្រធម្មជាតិ រាងកាយ និង ទស្សនវិជ្ជា។
4. **ការរួមចំណែក និងឥទ្ធិពល**
   - ការសង្កត់ធ្ងន់ទៅលើមនុស្សដែលល្អគ្រប់ជ្រុងជ្រោយមានការអប់រំផ្នែកអក្សរសាស្ត្រ។
   - សារៈសំខាន់នៃវិចារណញ្ញាណ។

**ង-អ៊ីសូក្រាត ៤៣៦-៣៨៨ មុនគ.ស. (ក្រិក)**

1. **ការតម្រង់ទិសខាងទស្សនវិជ្ជា**
   វោហារសាស្ត្រវិទូជាអ្នកអប់រំសិល្បៈនៃការថ្លែងសុន្ទរកថាក្នុងសេវាកម្មដោយខ្លួនឯង និងសង្គម។
2. **ទស្សនៈស្ដីពីធម្មជាតិមនុស្ស**
   មនុស្សមានថាមពល ដើម្បីប្រើប្រាស់ពាក្យសម្ដី សម្រាប់ការកែលម្អនយោបាយ និងសង្គម។
3. **ទស្សនៈទៅលើការអប់រំ និងកម្មវិធីសិក្សា**
   ការសិក្សាវោហារសាស្ត្រ បំណិនអក្សរសាស្ត្រជាមូលដ្ឋាន នយោបាយ ប្រវត្តិសាស្ត្រ ការថ្លែងទៅកាន់ទស្សនិកជន និងការនិយាយនៅក្នុងទីសាធារណៈ។
4. **ការរួមចំណែក និងឥទ្ធិពល**
   - ការប្រើប្រាស់ចំណេះដឹងក្នុងកិច្ចការសាធារណៈនិងក្នុងមគ្គុទ្ទេសក៍ភាពនយោបាយ។
   - ការអប់រំគ្រូ មានទាំងវិសាលភាពខ្លឹមសារ និងការប្រតិបត្តិ។

*(នៅមានត)*

*អនុបណ្ឌិត* **សូ សុធីរ**

# តើព្រះភក្ត្រព្រះព្រហ្មគំណាងនៃបាយ័ន មុខ ៤ មែនឬទេ?

មជ្ឈដ្ឋានភ្ញៀវដែលបានទស្សនាប្រាង្គប្រាសាទបុរាណរបស់ខ្មែរ តែងមានការកោតសរសើរប្រកបដោយភាពល្បីល្បាញនៃប្រាសាទបាយ័ន។ គេបានធ្វើការសន្និដ្ឋានដ៏ជាក់លាក់ថាប្រាសាទបាយ័ន គឺជានិមិត្តរូបនៃជាតិខ្មែរទាំងមូលឬជាដំបូលរួមមួយនៃការរួមរស់ដ៏សុខសាន្តនៃជំនឿរបស់ប្រជាពលរដ្ឋខ្មែរនាសម័យអង្គរតែម្តង។ជាពិសេសប្រវត្តិវិទូជាច្រើនបានយល់ដូចគ្នាថា ប្រាសាទបាយ័នជាពហុសាសនាដែលជាមជ្ឈមណ្ឌលនៃទីសក្ការៈបូជាព្រមគ្នានិងជាមួយគ្នាហៅថាសាមគ្គីភាពជាធ្លុងមួយជុំវិញព្រះរាជបល្ល័ង្គ ក្រោមការគ្រប់គ្រងរាជ្យដោយព្រះមហាក្សត្រជ័យវរ្ម័នទី៧។ ប៉ុន្តែនាពេលនេះដែរខ្ញុំលើកបង្ហាញតែបញ្ហាចម្លាក់ព្រះព្រហ្មដែលមានមុខ៤នេះ តើជាបដិមាមានមុខ៤ នៃកំពូលប្រាសាទបាយ័នមែនឬ?

មុននឹងចូលរួមបង្ហាញគំនិតដ៏ល្បីល្បាញរបស់ដូនតា ក៏ដូចជា ឧត្តមគតិបង្កប់ ដ៏មានតម្លៃរបស់បុព្វបុរសនៃប្រាសាទបាយ័ននោះ ក៏មានសំណួរថា អ្វីទៅហៅថាបាយ័ន?បើផ្អែកតាមការពន្យល់នៅក្នុង វចនានុក្រមខ្មែររបស់សម្តេចសង្ឃរាជ ជួន ណាត ទំព័រ៥៦៦ បោះពុម្ពឆ្នាំ ១៩៦៧ បានឲ្យដឹងថាៈបាយ័នប្រែថាបល្ល័ង្គឬព្រះទែន មានន័យថាប្រាសាទនេះជាទីតាំងបល្ល័ង្គតម្កល់ព្រះពុទ្ធរូបឬទេវរូប។ដូចនេះប្រាង្គប្រាសាទបាយ័នគឺជាកន្លែងប្រាសាទដែលមានបល្ល័ង្គសម្រាប់តម្កល់ព្រះពុទ្ធរូបឬទេវរូបជាទីសក្ការៈបូជា។ជាពិសេសទាំងខាងព្រាហ្មណ៍សាសនិកនិងទាំងពុទ្ធសាសនិក អាចអញ្ជើញទៅបូជនីយដ្ឋាននេះដូចគ្នាក្នុងការគោរពទៅតាមជំនឿរបស់ខ្លួន។

ជាក់ស្តែងដូចជាការគោរពព្រះសិវលិង្គ,ការគោរពព្រះវិស្ណុ ,ការគោរពព្រះព្រហ្ម ,ការគោរពព្រះពោធិសត្វលោកេស្វរៈ ,និងការគោរពព្រះពុទ្ធរូបជាដើម។ទាំងអស់នេះហើយដែលជាលក្ខណៈពិសេសនៃប្រាសាទបាយ័នដែលប្លែកជាងប្រាសាទដទៃទៀតនោះ ។

ទន្ទឹមនេះដែរ ចំពោះការតាំងបង្ហាញនៅទីដ៏ខ្ពស់ជាងគេ នៃកំពូលប្រាង្គប្រាសាទសម្រាប់សម្គាល់ថាជាប្រាសាទបាយ័ននោះគឺមានចម្លាក់មុខ៤ហើយបែរទៅរកទិសធំទាំង៤តែម្តង។ គ្រង់-ចំណុចនៃមុខ៤នេះហើយដែលជានិមិត្តរូបដ៏ខ្ពង់ខ្ពស់នៃអ្នកកាន់សាសនាព្រាហ្មណ៍ប្រកបដោយជំនឿយ៉ាងមោះមុតបំផុត។ ក្នុងខណៈនេះយើងលើកយកមុខ៤នេះសម្រាប់ធ្វើជាភស្តុតាងនៃអ្នកគោរពព្រហ្មញ្ញសាសនា ដែលមានការព្រមព្រៀងក្នុងចិត្តនិងជឿជាក់ថាជាមុខព្រះព្រហ្មរបស់ខ្លួនមែន ។

ការពិតព្រះព្រហ្ម ជាអាទិទេពដែលមានតួនាទីបង្កើតលោក ហើយព្រះអង្គមានមុខ៤ មានដៃ៤ តែមានដងខ្លួនតែមួយប៉ុណ្ណោះ។ជាក់ស្តែងដូចរូបចតនៃចម្លាក់ព្រះព្រហ្ម បានភ្ជាប់មកជាមួយនិងអត្ថបទនេះ មានប្រភពពីប្រាសាទភ្នំបូកដែលកសាងឡើងនៅចុងសតវត្សរ៍ទី៩ និងនៅដើមសតវត្សរ៍ទី១០ ដោយស្នាព្រះហស្តព្រះបាទយសោវរ្ម័នទី១ ក្នុងការឧទ្ទិសដល់ព្រហ្មញ្ញសាសនា។

ដូចនេះចំពោះព្រាហ្មណ៍សាសនិកដែលមានជំនឿក្នុងការគោរពព្រះព្រហ្ម ជាអាទិទេពច្បង

គេនោះនៅពេលដែលបានឃើញកំពូលប្រាសាទបាយ័នរំលេចចេញដោយមុខ៤យ៉ាងខ្ពស់ត្រដែត យ៉ាងនេះគឺហាក់ដូចជាមានការទទួលស្គាល់ជាផ្លូវការនៃការលើកតម្កើងព្រះព្រហ្មពិតប្រាកដដែល មិនអាចប្រកែកបានឡើយ។ទន្ទឹមនឹងជំនឿថាព្រះព្រហ្មជាអាទិទេពបង្កើតលោកនោះក៏មជ្ឈដ្ឋាន នានាក្នុងសង្គមខ្មែរនាសម័យអង្គរក៏ដូចជាសម័យបច្ចុប្បន្ននេះដែរតែងយល់ថាៈមាតាបិតាជាអ្នក បង្កើតបុត្រ។មានន័យថាមនុស្សទាំងអស់គ្រប់គ្នាលើលោកនេះតែងមានកំណើតមកដោយសារ មាតាបិតាជាអ្នកបង្កើត។ម្ល៉ោះហើយគេតែងបានលើកតម្កើងនូវគុណបំណាច់របស់មាតាបិតា ហៅថាមានព្រហ្មវិហារធម៌ទាំង៤ដល់កូនចៅប្រុសស្រី។គឺមុខទាំង៤នេះតំណាងឲ្យព្រហ្មវិហារទាំង៤ មាន មេត្តា, ករុណា, មុទិតា និងឧបេក្ខាដែលប្រជាពលរដ្ឋយើងបានចេះចាំបន្តមកដល់សព្វថ្ងៃនេះ។

សរុបមកព្រះភក្ត្រទាំង៤ របស់ព្រះព្រហ្មនៃប្រាសាទបាយ័នក៏ជាតំណាងឲ្យមុខនៃមាតាបិតា របស់យើងក្នុងការផ្ដល់ជូននូវព្រហ្មវិហារធម៌ទាំង៤ក្នុងការចិញ្ចឹមនិងថែរក្សាកូនចៅឲ្យមានការរស់ រាន មានការអភិវឌ្ឍប្រកបដោយ សិរីមង្គលនៅលើលោកនេះពិតប្រាកដ៕



បដិមាព្រះសិរព្រះព្រហ្ម
នៅប្រាសាទភ្នំបូក សតវត្សទី 9-10
បច្ចុប្បន្ន តាំងនៅសារមន្ទីរហ្គីមេ (ប៉ារីស)

**លោក លី ហាក់សេង**
អតីតអធិការបឋមសិក្សាខេត្តតាកែវ (និវត្តន៍ជន)

# ប្រវត្តិនៃជនជាតិជ្វីហ្វ (អ៊ីស្រាអែល)

## I. ប្រវត្តិនៃប្រជាជាតិអ៊ីស្រាអែល:

ប្រវត្តិនៃជនជាតិជ្វីហ្វ(ឬអ៊ីស្រាអែល) ដែលជាប្រជាជាតិតូចមួយ ប៉ុន្តែមានឥទ្ធិពលខ្លាំងដល់វប្បធម៌និងផ្នត់គំនិតរបស់មនុស្សជាច្រើនរហូតមកទល់នឹងពេលបច្ចុប្បន្ន។ កាលណាគេនិយាយពីអរិយធម៌នៃតំបន់មេឌីទែរ៉ាណេសម័យបុរាណ គេមិនអាចមិននិយាយបានទេអំពីប្រវត្តិរបស់ជនជាតិតូចមួយដែលមានឥទ្ធិពលខ្លាំងនៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិជាពិសេសឥទ្ធិពលខាងមនោ-គមវិជ្ជាសាសនានោះគឺជាជនជាតិជ្វីហ្វ។ ការស្វែងយល់អំពីជនជាតិជ្វីហ្វសម័យបុរាណក៏ជាមូលដ្ឋានដ៏សំខាន់ដែរ ដើម្បីយល់ពីជម្លោះនៅដើមបូព៌ានាពេលបច្ចុប្បន្ននេះ។ជនជាតិជ្វីហ្វសម័យបុរាណឈ្មោះថា ហេព្រើ (Hebreux) នោះថ្វីដ្បិតតែរស់នៅក្បែរឆ្នេរសមុទ្រក្នុងតំបន់មេឌីទែរ៉ាណេក៏ប៉ុន្តែមិនមែនជាអ្នកជំនាញខាងដើរសមុទ្រដូចអរិយធម៌មេឌីទែរ៉ាណេផ្សេងទៀតដូចជា ក្រិក កោះក្រែត និងហ្វេនីស៊ីនោះទេ។ជនជាតិជ្វីហ្វសម័យដើម គឺជាជនជាតិដែលរស់នៅតាមបែបកុលសម្ព័ន្ធនៃមនុស្សសម័យបុរេប្រវត្តិដោយផ្លាស់ទីកន្លែងមួយនៅចន្លោះប្រទេសអេហ្ស៊ីបនិងមេសូប៉ូតាមី។ ប្រវត្តិប្រជាជាតិជ្វីហ្វបានចាប់ផ្តើមឡើងកាលពីជាង៣ពាន់ឆ្នាំមុននៅពេលដែលជនជាតិជ្វីហ្វភៀសខ្លួនចេញពីភាពជាទាសករនៅអេហ្ស៊ីប ហើយធ្វើដំណើរកាត់តាមវាលរហោស្ថានឆ្ពោះទៅកាន់ទឹកដីកាណាន (អ៊ីស្រាអែល និងប៉ាឡេស្ទីនបច្ចុប្បន្ន)។

ដំណើររឿងនេះត្រូវបានរ៉ាយរ៉ាប់យ៉ាងក្បោះក្បាយនៅក្នុងគម្ពីរតូរ៉ា (Torah) របស់ពួកជ្វីហ្វ និងនៅក្នុងសញ្ញាចាស់នៃគម្ពីរប៊ីបរបស់គ្រិស្តសាសនា។ ក៏ប៉ុន្តែអ្នកប្រវត្តិសាស្ត្រនិងអ្នកបុរាណវិទ្យានៅមិនទាន់មានការឯកភាពគ្នានៅឡើយជុំវិញដំណើររឿងនេះ។នៅក្នុងទឹកដីកាណាន ជនជាតិជ្វីហ្វ(ឬហេព្រើ)បានចាប់របរកសិកម្មបង្កើតជារដ្ឋ រួចហើយបានសាងសង់បុរីជាទីសក្ការៈមួយគឺទីក្រុងយេរ៉ូសាឡឹម។ នៅខាងត្បូងទីតាំងដែលជនជាតិជ្វីហ្វរស់នៅមានជនជាតិមួយទៀតដែលជាសត្រូវរបស់ពួកជ្វីហ្វគឺជនជាតិហ្វីលីស្ទីន។ ក្រុងយេរ៉ូសាឡឹមរបស់ពួកជ្វីហ្វត្រូវបានពួកបាប៊ីឡូនកម្ទេចចោលនៅឆ្នាំ៥៨៨មុនគ.សហើយជនជាតិជ្វីហ្វទាំងអស់ត្រូវបានគេជម្លៀសចេញពីទឹកដីកំណើតយកទៅបាប៊ីឡូន រហូតក្រោយពេលដែលអាណាចក្រពែរស៍វាយដណ្តើមកាន់កាប់បាប៊ីឡូន ទើបអធិរាជពែរស៍អនុញ្ញាតឲ្យជនជាតិជ្វីហ្វវិលត្រឡប់ទៅប្រទេសកំណើតរបស់ពួកគេវិញ។

ក៏ប៉ុន្តែនៅឆ្នាំ៦៣មុនគ.សទឹកដីអ៊ីស្រាអែលក៏ដូចជាទឹកដីភាគច្រើនផ្សេងទៀតនៅក្នុងតំបន់ត្រូវបានអាណាចក្ររ៉ូមកាន់កាប់ត្រួតត្រា។ ជនជាតិជ្វីហ្វមិនសុខចិត្តទ្រាំរស់នៅក្រោមការ ត្រួតត្រារបស់អាណាចក្ររ៉ូមក៏បាននាំគ្នាងើបឡើងបង្កើតជាចលនាបះបោរនឹងអាជ្ញាធរនៃអាណានិគមរ៉ូម។ ក៏ប៉ុន្តែចលនាបះបោរនេះត្រូវបានទាហានរ៉ូមវាយបំបាក់។ ក្រុងយេរ៉ូសាឡឹមត្រូវបានវាយកម្ទេច-ចោល។ ជនជាតិជ្វីហ្វទាំងអស់ត្រូវបានបណ្តេញចេញពីទឹកដីកំណើតសាជាថ្មីម្តងទៀត ហើយដែនដី អ៊ីស្រាអែលទាំងមូលត្រូវបានអាណាចក្ររ៉ូមប្តូរឈ្មោះទៅជាដែនដីប៉ាឡេស្ទីនវិញ។

មូលហេតុដែលអាណាចក្ររ៉ូមប្តូរឈ្មោះដែនដីអ៊ីស្រាអែលទៅជាប៉ាឡេស្ទីននេះទំនងជាមានបំណងចង់ដាក់ទោសដល់ជនជាតិជ្វីហ្វ ដោយសារតែ "ប៉ាឡេស្ទីន" គឺជាឈ្មោះក្លាយពី "ហ្វីលីស្ទីន" ដែលជាជនជាតិរស់នៅខាងត្បូងជាប់នឹងទឹកដីអ៊ីស្រាអែល ហើយជាសត្រូវចាស់ឆ្នាំរបស់ពួកជ្វីហ្វ។ ចាប់តាំងពីត្រូវបានបណ្តេញចេញដោយអាណាចក្ររ៉ូមកាលពីជាង២ពាន់ឆ្នាំមុន ជនជាតិ

ជ្វីហ្វត្រូវបែកខ្ញាត់ខ្ចាយទៅរស់នៅជាសហគមន៍ជនជាតិជ្វីហ្វនៅបរទេស ហើយលែងអាចវិលត្រឡប់ទៅកាន់ទឹកដីកំណើតបង្កើតជាប្រទេសជាតិវិញជារៀងរហូត។ នៅក្នុងអំឡុងពេលនោះអស់រយៈពេលប្រមាណជា២ពាន់ឆ្នាំ ទឹកដីអ៊ីស្រាអែល (ដែលប្ដូរទៅជាប៉ាឡេស្ទីន) លែងស្គាល់ឯករាជ្យ ដោយត្រូវមហាអំណាចប្ដូរដៃគ្នាគ្រប់គ្រងពីមួយទៅមួយ ក្នុងនោះភាគច្រើនគឺក្រោមការកាន់កាប់របស់មហាអំណាចកាន់សាសនាអ៊ីស្លាម។ ចុងក្រោយនៅដើមសតវត្សរ៍ទី២០ទឹកដីប៉ាឡេស្ទីននេះត្រូវស្ថិតក្រោមអាណាព្យាបាលរបស់ចក្រភពអង់គ្លេស។

នៅសតវត្សរ៍ទី១៩ទ្វីបអឺរ៉ុបទាំងមូលបានផ្ដើមពើបប្រទះនឹងបាតុភាពពីរ។ទីមួយគឺការលេចឡើងយ៉ាងផុសផុលនៃចលនាជាតិនិយមជ្រុល និងទីពីរគឺការស្អប់ខ្ពើមពួកជ្វីហ្វខ្លាំងឡើងៗ ។ បាតុភាពប្រកបដោយគ្រោះថ្នាក់ទាំងពីរនេះបានអង្រួនស្មារតីជនជាតិជ្វីហ្វក្នុងបណ្ដាប្រទេសអឺរ៉ុបឲ្យភ័យ ឲ្យភ្ញាក់ខ្លួននិងឲ្យផ្ដើមមានមហិច្ឆតានយោបាយនិងទឹកដី។និយាយបែបផ្សេង ពួកជ្វីហ្វបានផ្ដើមមានគំនិតចង់វិលត្រឡប់ទៅរស់នៅក្នុងទឹកដីដូនតារបស់ពួកគេវិញ ចង់វិលត្រឡប់ទៅកាន់ប៉ាឡេស្ទីនវិញ។ នៅក្នុងបរិបទបែបនេះហើយដែលនៅចុងសតវត្សរ៍ទី១៩ ជនជាតិជ្វីហ្វម្នាក់ Théodore Herzl បានបង្កើតចលនាមួយឡើងគឺចលនាស៊ីយ៉ូននិស្ដ(Sionise)។ ស៊ីយ៉ូន(Sion) ជាឈ្មោះនៃទួលមួយនៅក្រុងយេរ៉ូសាឡឹម(Jérusalem) ក្នុងដែនដីប៉ាឡេស្ទីន។ ចលនាស៊ីយ៉ូននិស្ដរបស់ Théodore Herzl មានគោលដៅមួយធំនោះគឺប្រមូលផ្ដុំជនជាតិជ្វីហ្វមកពីគ្រប់ទីកន្លែងរួចហើយកេណ្ឌគ្នាទៅបង្កើតប្រទេសមួយនៅលើទឹកដីប៉ាឡេស្ទីន។ នៅឆ្នាំ១៩១៤ មុនសង្គ្រាមលោកលើកទីមួយបានផ្ទុះឡើងដោយសារតែសកម្មភាពរបស់ចលនាស៊ីយ៉ូននិស្ដ ចំនួនជនជាតិជ្វីហ្វដែលបានចូលទៅតាំងលំនៅឋាននៅក្នុងដែនដីប៉ាឡេស្ទីនបានកើនទៅដល់៨៥.០០០នាក់។ ក៏ប៉ុន្តែគេត្រូវរង់ចាំបីឆ្នាំ ចាំដល់ឆ្នាំ១៩១៧ ទើបឃើញប្រទេសមុនគេបង្អស់ក្នុងលោកគឺ ប្រទេសអង់គ្លេសចេញមុខគាំទ្រជាផ្លូវការចលនាស៊ីយ៉ូននិស្ដរបស់ Théodore Herzl។កាលណោះលោក Balfour រដ្ឋមន្ត្រីក្រសួងការបរទេសនៃអង់គ្លេស ដែលជាប្រទេសមួយមានឥទ្ធិពលខ្លាំងនៅក្នុងភូមិភាគបូព៌ាបានថ្លែងគាំទ្រឲ្យមានមណ្ឌលជនជាតិជ្វីហ្វមួយនៅលើទឹកដីប៉ាឡេស្ទីន។ការថ្លែងបែបនេះរបស់លោក Balfour បាននាំមកនូវផលវិបាកធ្ងន់ធ្ងរមែនទែនសម្រាប់ប្រវត្តិសាស្ត្រ។ពីព្រោះចាប់ពីពេលនោះមកនៅខាងប្រជាជនអារ៉ាប់ក្នុងភូមិភាគដើមបូព៌ា គឺជាការផ្ដើមចងកំហឹងទៅលើចក្រភពអង់គ្លេសនិងការផ្ដើម តស៊ូខ្ទប់មិនឲ្យពួកជ្វីហ្វចូលមកតាំងលំនៅឋានក្នុងទឹកដីប៉ាឡេស្ទីន។

នៅខាងជនជាតិជ្វីហ្វវិញ គេបានចាត់ទុកថាការថ្លែងរបស់លោកBalfourគឺជាការទទួលស្គាល់ជាផ្លូវការនូវមហិច្ឆតានយោបាយរបស់ចលនាស៊ីយ៉ូននីស្ដ។ពួកជ្វីហ្វបានផ្ដើមមានជំនឿថាការបង្កើតប្រទេសអ៊ីស្រាអែលមួយនៅលើដីប៉ាឡេស្ទីន លែងជាការស្រមើស្រមៃទៀតហើយ គឺជាសុបិនដែលអាចក្លាយជាការពិតបាន។



ក្រុងយេរូសាឡឹមសម័យកាលបច្ចុប្បន្ន



គំនូរបង្ហាញពីការកម្ទេចក្រុងយេរូសាឡឹមដោយសារអាណាចក្ររ៉ូម

(នៅមានត)

**រៀបរៀងដោយ លោក គួយ សុគាន**

(ដកស្រង់ពីវិទ្យុបារាំង RFI)

## ចរិត

រូបល្អចរិតល្អ
ទៅណាក៏មានភ័ព្វ
រូបល្អអន់ចរិត
មិនថានៅក្រុងស្រែ
បានរូបបានចរិត
ទៅណាគេជឿជាក់
រៀនខ្ពស់ដល់បណ្ឌិត
អាចគ្មានអ្នកចង់ក្បែរ

ទោះបីក្រមានគេរាប់
លាភចូលជាប់គេចង់ក្បែរ។
មានៈចិត្តពិបាកកែ
គេមិនក្បែររាប់រក់ទាក់។
មានអ្នកស្និទ្ធមិនស្ទើរស្នាក់
ចាស់ហៅអ្នកមានមន្តស្នេហ៍។
ជំនាញពិតខ្លាំងពូកែ
បើពូកែ ចរិតយ៉ាប់។

**សារព័ត៌មានថ្មីៗ**

## ទម្រង់វប្បធម៌អរូបីនៃ
## ទេវកថា កូរសមុទ្រទឹកដោះ (តចប់)

កាលបើសកម្មភាពចាប់ទាញសត្វពស់ ដើម្បីបង្វិលភ្នំមន្ទរៈកាន់តែមានសន្ទុះខ្លាំងទៅៗ នាំឲ្យខ្លួនប្រាណរបស់ពស់វ៉ាសុគី ត្រូវរឹតរួតយ៉ាងខ្លាំងបណ្ដាលឲ្យក្អួតពិសចេញមកខាងក្រៅ។ ពិសពស់នេះមានគ្រោះថ្នាក់ជាទីបំផុត សម្រាប់ពិភពទាំងឡាយ ក្នុងចក្រវាឡទាំងមូល ពីព្រោះបើវាធ្លាក់ទៅលើឋានណាមួយគឺឋាននោះនឹងត្រូវឆាបឆេះវិនាសអន្តរាយភ្លាមមួយរំពេច។ម៉្យាងទៀតក៏គ្មានអាទិទេពអង្គណាអាចបង្ក្រាបពិសពស់នេះបានឡើយ។ហេតុតែភ័យខ្លាចពិសពស់ដែលបំផ្លាញពិភពទាំងឡាយនោះក្រុមគេទាំងពីរ ក៏បាននាំគ្នាទៅសុំអង្វរព្រះសិវៈដើម្បីជួយអន្តរាគមន៍ទៀត។ព្រះសិវៈទ្រង់បានពិចារណាយ៉ាងច្បាស់ពីផលបង្កឡើងពីឥទ្ធិពលពិសពស់ដ៏មានអានុភាពនេះ។ព្រះសិវៈបានទទួលការអង្វរពីក្រុមកូរសមុទ្រទឹកដោះ។ព្រះអង្គទ្រង់សម្រេចព្រះទ័យយល់ព្រមកំចាត់ពិសពស់ទាំងនោះចេញ ទោះដឹងថាពិសពស់នេះនឹងបង្កផលអាក្រក់ដល់ទ្រង់ក៏ដោយ។ ខណៈនោះព្រះនាងឧមា ជាព្រះមហេសីរបស់ព្រះអង្គគ្រាន់តែឮការសម្រេចព្រះទ័យរបស់ព្រះអង្គភ្លាម ព្រះនាងក៏កើតក្ដីបារម្ភយ៉ាងខ្លាំង ព្រោះខ្លាចស្វាមីរបស់ខ្លួនត្រូវអន្តរាយដោយសារឥទ្ធិពលពិសពស់នេះ។ហេតុនេះហើយ ទើបព្រះនាងមិនហ៊ានទៅណាឃ្លាតឆ្ងាយពីព្រះសិវៈឡើយ។

ក្រោយពីព្រះសិវៈទ្រង់យល់ព្រមជួយក្រុមកូរសមុទ្រទឹកដោះទាំងនោះភ្លាមទ្រង់បានក្បង់ពិសពស់នោះដាក់ចូលទៅក្នុងមាត់។ ពេលនោះព្រះនាងឧមា បានស្ទុះទៅចុចបំពង់ករបស់ព្រះអង្គជាប់ដើម្បីទប់កុំឲ្យពិសពស់ទាំងនោះចូលទៅក្នុងព្រះកាយ បើមិនដូច្នោះទេព្រះអង្គនឹងត្រូវទទួលនូវក្ដីអន្តរាយដល់ជីវិតភ្លាមៗ។ ការណ៍ដែលព្រះនាងឧមា ស្ទុះទៅចុចបំពង់កព្រះសិវៈទប់ពិសពស់បានទាន់ពេល ទើបធ្វើឲ្យពិសពស់ដែលមានឈ្មោះហាឡា ហាឡា ទាំងនោះស្ថិតនៅត្រឹមបំពង់កមិនអាចចូលក្នុងព្រះកាយព្រះអង្គបាន។មហិទ្ធិឫទ្ធិដ៏អស្ចារ្យនៃពិសពស់ឈ្មោះអនន្តៈពេលនៅត្រឹមបំពង់កធ្វើឲ្យព្រះភ័ក្ត្រព្រះសិវៈក្លាយជាពណ៌ខៀវក្រមៅ ព្រះភ័ក្ត្រព្រះសិវៈមានទិដ្ឋភាពបែបនេះត្រូវបានគេដាក់ព្រះនាមជា “និលកន្ធ” មានន័យថា ព្រះសិវៈក្នុងរូបសណ្ឋាន “ព្រះ-ភ័ក្ត្រពណ៌ខ្មៅ” ។ ពិសពស់ដែលកំពុងស្ថិតក្នុងបំពង់កព្រះសិវៈ បានធ្វើឲ្យព្រះអង្គទ្រង់ទទួលអា-រម្មណ៍ក្ដៅអន្ទះអន្ទែងយ៉ាងខ្លាំងរហូតធ្វើឲ្យព្រះអង្គទ្រាំពុំបាន។ខណៈនោះព្រះអង្គក៏សម្រេចព្រះទ័យចាប់ព្រះចន្ទយកមកដាក់ពីលើក្បូងសក់របស់ព្រះអង្គដើម្បីធ្វើឲ្យព្រះកាយរបស់ទ្រង់ត្រជាក់វិញ។ ហេតុនេះហើយទើបមានចម្លាក់ “ព្រះកេស” ព្រះសិវៈ ឃើញមានចំណិតព្រះចន្ទលើក្បូងសក់ជាតឹកតាង។

ក្រោយពីព្រះសិវៈធ្វើអន្តរាគមន៍ ដោះស្រាយកំអែពិសពស់នេះរួចរាល់ សកម្មភាពកូរទឹកសមុទ្របានបន្តដំណើរការទៅមុខទៀតរហូត។ប៉ុន្តែមុនពេលកូរទឹកសមុទ្រជិតឈានដល់ទីបញ្ចប់

ក៏ស្រាប់តែលេចចេញនូវសត្វលោកមួយចំនួនជាបន្តបន្ទាប់។ដំបូងចេញសត្វសេះមួយក្បាល ឈ្មោះ "ឧច្ចៃស្រវាស" ហើយត្រូវបានព្រះសូរ្យ ឬព្រះអាទិត្យទ្រង់ចាប់យកធ្វើជាយានជំនិះផ្ទាល់របស់ទ្រង់។បន្ទាប់មកលេចចេញសត្វដំរីក្បាលពណ៌ឈ្មោះ"ឰរាវត"ត្រូវបានព្រះឥន្ទ្រយកមកធ្វើជាជំនិះផងដែរ។បន្ទាប់មកទៀតក៏លេចចេញអាទិទេពមួយអង្គព្រះនាមស្រី ឬលក្ស្មី ដែលមានសម្ផស្សស្រស់ស្អាតព្រះវិស្ណុទទួលយកជាភរិយា។ចុងក្រោយបានលេចចេញទេពអប្សរឬអប្សរាជាច្រើនសន្ធឹកសន្ធាប់ហោះហើររេរាំពាសពេញអាកាសចេញមកអបអរសាទរដល់ក្រុមទាំងពីរដែលបានសម្រេចលទ្ធផលដ៏ធំធេង គឺការទទួលបាន "ទឹកអម្រឹត"។ពិសេសសំដែងការអបអរសាទរ និងថ្វាយព្រះពរជ័យដល់ព្រះវិស្ណុ និងព្រះសិវៈដែលជានិច្ចកាលព្រះអង្គតែងតែបានជួយធ្វើអន្តរាគមន៍ រហូតធ្វើឲ្យការកូរទឹកសមុទ្រយកទឹក "អម្រឹត"សម្រេចបានជោគជ័យយ៉ាងត្រចះត្រចង់នេះ។

ចុងបញ្ចប់ពួកទេវៈនិងពួកអសុរៈក៏ទទួលបាន"ទឹកអម្រឹត" ដូចបំណងមែន។"ទឹកអម្រឹត" នេះស្ថិតក្នុងក្អមមួយ ហើយពួកគេត្រូវធ្វើការបែងចែកទឹកអម្រឹតនេះឲ្យដល់អ្នកកូរទឹកសមុទ្រទាំងអស់គ្នា។ព្រះវិស្ណុនៅតែដើរតួនាទីសំខាន់និងជាអាជ្ញាកណ្ដាលសម្រាប់ការបែងចែកនេះ។ ប៉ុន្តែដោយមានភាពលំអៀង ព្រះអង្គបានប្រែព្រះកាយជាស្រីរបាំរូបស្រស់ម្នាក់ មានឈ្មោះថា "មោហិនី"។ស្រីមោហិនីបានយកក្អមមានទឹកអម្រឹតនេះមកកណ្ដៀតលើចង្កេះ រួចចាប់ផ្ដើមច្រៀងរាំ នៅចំកណ្ដាលក្រុមទេវៈនិងអសុរៈដែលកំពុងឈរព័ទ្ធជុំវិញ។ព្រះវិស្ណុធ្វើបែបនេះគឺក្នុងបំណងបន្លំភ្នែកពួកអសុរៈនិងធ្វើឲ្យពួកគេភ្លេចគិតពីការចង់បានទឹកអម្រឹតផឹក។ពេលនោះ ព្រះវិស្ណុដែលកាឡាខ្លួនជាស្រីមោហិនី បានលួចចែកទឹកអម្រឹតឲ្យពួកទេវៈផឹកទាំងអស់។ ចំណែកពួកអសុរៈគ្មានសំណាងទទួលបានទឹកអម្រឹតនេះផឹកឡើយ។

សុក្រាចារ្យជាអ្នកឆ្លាតវៃ យល់ហេតុការណ៍នេះក៏ប្រើមន្តអាគមរបស់ខ្លួនលបប្រែកាឡាបន្លំជាទេវៈ ហើយលបចូលទៅបន្លំឈរជាមួយពួកទេវៈទាំងអស់ ដើម្បីរង់ចាំទទួលទឹកអមតៈពីព្រះវិស្ណុដែរ។ គ្រាន់តែដឹងភ្លាមព្រះវិស្ណុក្រោធនឹងសុក្រាចារ្យយ៉ាងខ្លាំងដែលហ៊ានលួចបន្លំខ្លួនជាទេវៈ ព្រះអង្គចាប់យកកងចក្រគប់សំដៅទៅសុក្រាចារ្យ ធ្វើឲ្យដាច់ខ្លួនជាពីរកំណាត់ភ្លាម។ចំណែកខ្លួនរបស់សុក្រាចារ្យទាំងពីរកំណាត់នោះក្លាយជាអាទិទេពចំនួនពីរអង្គខុសគ្នាដែរ។ ចំណែកខាងក្បាលក្លាយជាអាទិទេពមួយអង្គឈ្មោះ"រាហូ"។រីឯចំណែកខាងខ្លួនវិញក្លាយជាអាទិទេពមួយអង្គទៀតឈ្មោះ"កេទុ"។ ហេតុការណ៍ដាច់ខ្លួនជាពីរចំណែកយ៉ាងអាណោចអធ័មបែបនេះ គឺបណ្ដាលមកពីការអុជអាលរបស់ព្រះចន្ទ និងព្រះអាទិត្យ។ហេតុនេះហើយទើប "រាហូ" មានការចងកំហឹងនឹង អាទិទេពទាំងពីរអង្គនេះយ៉ាងខ្លាំងហើយតែងតែប៉ុនប៉ងតាមដានសងសឹកវិញជានិច្ច។(ខ្មែរយើងនិយមហៅថា "រាហូចាប់ចន្ទ" នេះឯង)។

រីឯដំណើររឿងក៏បានស្ទេះត្រឹមនេះ។រឿងនេះគ្រាន់តែជាផ្នែកមួយនៃ "មហាភារតៈ" ដែលត្រូវបានដកស្រង់វគ្គមួយនៃការបើកយុទ្ធនាការនៃការកូរសមុទ្រទឹកដោះតែប៉ុណ្ណោះ៕



ចម្លាក់នៅលើជញ្ជាំងខាងកើតនៃប្រាសាទអង្គរវត្ត



សត្វសមុទ្រទាំងឡាយកំពុងរត់រឺដោយឥទ្ធិពល
នៃការកូរសមុទ្រទឹកដោះ



សុក្រាចារ្យទាញក្បាលវាសុគី



ផ្ដែរទ្វារនៃប្រាសាទព្រះធាតុបាពយណ៍ ស្រុកស្រីសន្ធរ



ព្រះកេសព្រះសិរៈ



ចម្លាក់រាហូនៅលើផ្ដែរទ្វារនៃប្រាសាទស្ទឹងខាងកើត
ខេត្តបាត់ដំបង

*លោកស្រី ម៉ៅ តាន់ណារី*
*អនុប្រធានការិ.នៃនាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា*

# រឿងទាក់ដំរី (ត)

ដល់ប្រទះនឹងហ្វូងដំរីព្រៃ ហ្មទាំងឡាយក៏បរផ្ទាក់សម្រុកចូលទៅក្នុងហ្វូងដំរីដែលមានដំរីពី ៤០ទៅ៦០ហើយស្រែកសន្ធាប់បង្អើលកងរំពង។ ពេលនោះ ដំរីព្រៃភ័យស្លន់រត់បែកខ្ញែកគ្នាប្រសេចប្រសាច ។ លុះឃើញឱកាសល្អហើយ ទើបពួកហ្មបោះព្រ័ត្រទៅទាក់កូនដំរីណាដែលខ្លួនស្រឡាញ់តែរៀងខ្លួន ( តូចពេកខ្លាចស្លាប់ ធំពេកក្រែងការពារពុំឈ្នះ គឺយកតែល្មម )។ កាលណាព្រ័ត្រប្រកាំទាក់ជាប់ជើងកូនដំរីហើយ គង្វាលលើកព្រ័ត្រទាំងចង្វាយបោះទៅលើដី ហើយលោតចុះទៅតាមដើម្បីចាប់យកកន្ទុយព្រ័ត្រ ចងនឹងគល់ឈើ។ ចុងព្រ័ត្រនេះអ្នកខ្លះមានចងស្នែងរង ឬក្រងារធ្វើអំពីស្នែងក្របីរោលភ្លើងពត់ឲ្យខុបក្ងក់ គេមិនយកដែក ឬឈើធ្វើទេខ្លាចបាក់ ។ តែកាលណាជាប់បាពសាវអូសព្រ័ត្រទៅឲ្យស្នែងនេះផ្ដក់ជាប់នឹងគល់ឈើមិនអាចទៅឆ្ងាយទៀតបាន។ ពេលនោះពួកស្ដព្រៃវាមិនមែនបណ្ដោយឲ្យគេចាប់កូនចៅវាតាមអំពើចិត្តទេ រួចពីផ្អើលមួយភ្លែត វាត្រឡប់មកតដៃនឹងផ្ទាក់ ដើម្បីដណ្ដើមយកដំរីពីប្រកាំវិញ។ ខណៈនោះ ហ្មរត់ឡើងលើខ្នងផ្ទាក់ចាប់ដាវនឹងពូថៅតដៃនឹងដំរីព្រៃ។ គង្វាលគិតតែវាយចាក់ផ្ទាក់ឲ្យរត់ដេញដំរីព្រៃទាល់តែបាក់បប រត់ព្រាត់ប្រាសទៅឆ្ងាយ។ ពេលដែលបាពសជាប់ប្រកាំហើយរត់ ហ្មអាចសំគាល់បានថា បាពសនោះមានកម្លាំងប៉ុនណា។ តែកាលណាជាប់ប្រកាំហើយ បាពសនោះរត់ទាល់តែដួលដេក ហ្មគេប្រញាប់លក់ចោល បើទុកទៅមុខជាស្លាប់ខាតប្រយោជន៍។ ម្យ៉ាងទៀត ដំរីដែលទើបនឹងទាក់បាននោះ បើពួកហ្មឈ្លោះប្រកែកគ្នាពីរឿងបែងភាគមិនស្មើនោះ គេត្រូវលក់ចោលដែរ សុខចិត្តឲ្យខាតខ្លះតែទុកទៅដំរីនោះអាយុខ្លី ។

តាមទម្លាប់ ហ្មនឹងគង្វាលដែលធ្វើការរួមគ្នា ត្រូវទាក់ឲ្យបានបាពស ៣ គឺបាពសមួយចំណែកហ្ម បាពសមួយចំណែកម្ចាស់ផ្ទាក់ បាពសមួយទៀតចំណែកគង្វាល ។

ឯការថែរក្សាកូនបាពសបានស្រេចនៅលើគង្វាល។ មួយថ្ងៃៗ គង្វាលជិះផ្ទាក់ទៅអែបមើលទន្លឹងពីរ បីដងអែបនាំបាពសទៅឲ្យផឹកទឹក ទៅលាងទឹក។ ម្យ៉ាងទៀត ការនាំបាពសពីព្រៃជាការលំបាកក្រៃលែង ព្រោះថាធម្មតាសត្វព្រៃមិនមែនចង់ចូលទៅនៅស្រុក ឲ្យមនុស្សធ្វើបាបគ្រប់ពេលវេលាទេ ណាមួយវាព្រាត់ហ្វូង ព្រាត់មេ បងប្អូនដែលធ្លាប់សប្បាយជាមួយគ្នាផង។

កាលមកដល់ស្រុកភូមិហើយ ហ្មក៏ដាក់ត្រណមពីប្រពន្ធចេញ រួចបង្គាប់ឲ្យគង្វាលរកឈើណាធ្វើជាអាជ្ញា ឬ សន្លុងសម្រាប់ផ្សាំងបាពស។ រកបានហើយ គង្វាលយកបាពសទៅចងព្រយុងបង្អត់ស្មៅ៣-៤ថ្ងៃ ឲ្យហេវកុំឲ្យក្លាពេក ជាហេតុនាំឲ្យងាយផ្សាំងហើយគង្វាលបរផ្ទាក់ទៅអែបបង្ហាត់បន្តិចម្ដងៗ ទាល់តែមនុស្សពាល់បានឥតផ្អើល។ ក្រោយពីនោះមានការបង្ហាត់ឲ្យចេះស្ដាប់ភាសាទ្រមាក់ដូចជាថា៖

ហាវ១ = ឈប់
ដុន១ = ថយ
ជូន១ = លើកជើងមុខ
ទ្រាម = ក្រាប
ដាក់ = លុតជង្គង់ក្រោយ
ដៃ = ហាមមិនឲ្យបោចពោច
កាន់ = ចាប់ កាច់ ឬ ដក ។ ល ។

លុះបារាសចេះស្ដាប់បង្គាប់លែងផ្អើលហើយ ទើបហ្មរៀបចំធ្វើពិធី"ចាប់ជើង"ឲ្យឈ្មោះដំរីនោះ ។ តាមសេចក្ដីឲ្យការរបស់លោក **ខូង អ៊ួច** អតីតមេឃុំ១អង្គាញ់ ស្រុកព្រៃកប្បាស ខែត្រតាកែវ ដែលធ្លាប់បានឃើញគេធ្វើពិធីនេះនៅតំបន់របស់លោកប្រមាណជា៥០ឆ្នាំ មកហើយនោះ (គិតកាលពីឆ្នាំ ១៩៦៣មកម្ល៉េះ) ថាមានធ្វើច្រម៤ បាយសិង្សាដក៏ដាក់ក្នុងកន្ទោង៤ ស្លាក៤ មានសរសេរឈ្មោះសត្វតាមម្ចាស់ស្រឡាញ់ ហើយដឹកសត្វនោះមកបញ្ឈរនៅក្បែរកន្លែងពិធី។ ហ្មតាំងចាប់អុជទៀន-ធូបបួងសួងអធិដ្ឋានឡើងថា:

"ឱតេជៈ ថ្ងៃនេះជាថ្ងៃជាពេលាល្អ ព្រះភូមករ ព្រះធរណី អ្នកតាចាស់ស្រុក ម្រេញគង្វាលដែលរក្សា ទឹក ដី បឹងបួ ទួលទីនេះ។ឥឡូវនេះ ខ្ញុំត្រូវការឲ្យឈ្មោះសត្វដំរីនេះ បើឈ្មោះណាដែលសុខចម្រើនដល់ម្ចាស់ទ្រព្យ សូមឲ្យសត្វនេះ ដើរជាន់ស្លាកឈ្មោះនោះមុនគេទៅ" ។

លុះបួងសួងគ្រប់៣ដងហើយ ទើបដឹកដំរីដើរប្រទក្សិណកន្លែងពិធី៣ជុំ។ បើដំរីនោះជាន់លើស្លាកឈ្មោះណាក៏ហៅដំរីតាមឈ្មោះនោះទៅ មានឈ្មោះ អាជៀប អាស្ដុ អាកន្លង់ មេក្រពុំ ជាដើម ហើយគេនាំគ្នាស៊ីផឹកសប្បាយទៅ។ បើអ្នកណាទៅកន្លែងនោះហើយ មិនព្រមទទួលបរិភោគចំណីអាហារជាមួយនឹងគេតែដល់ក្រោយមក ដំរីគេឈឺ គេថាមកពីអ្នកនោះមិនព្រមទទួលអំណរគេ។ នេះជាទំនៀមក្នុងឱកាសពិធីដាក់ឈ្មោះឲ្យដំរី ។

ចំណែកនៅខាងខែត្រពោធិ៍សាត់វិញ ពិធីនេះធំប្រហែលនឹងរៀបអាពាហ៍ពិពាហ៍មួយដែរ ប៉ុន្តែគេច្រើនហៅ"សែនផ្ដាច់ព្រៃ"ឲ្យឈ្មោះដំរីទៅវិញ ហើយការឲ្យឈ្មោះទៀតមិនមែនធ្វើផ្សងតាមកន្ទោង ឬ ស្លាកទេ គឺស្រេចនៅលើការស្រឡាញ់របស់ប្រពន្ធហ្ម។ ឯរបៀបសំណែនក៏ខុសគ្នាដែរ ។

របៀបខាងខែត្រពោធិ៍សាត់ មានបាយសីប៉ាក់ឆាម ព្រៃត ស្លាធម៌១គូ ទៀន៥ ធូប៥ ជមបង្អែម ចម្អាប គូឆ្វេង ស្លាំ សំពត់ផ្នត់ មាន់ស្ងោរ និងស្រា១ដប ព្រមទាំងមានធ្វើពិធី ប្រោះព្រំទឹកមន្តរំដោះចង្រៃបារាសផង ។

(នៅមានត)

**លោក ចែម ផាន**
**អធិការបឋមសិក្សា(ចូលនិវត្តន៍)**



# ចិត្តវិទ្យាអប់រំ

## គ្រូបង្រៀន ជាអ្នកសម្របសម្រួលគឺ មិនមែនបង្ខំសិស្សឲ្យធ្វើតាមខ្លួនទាំងស្រុងឡើយ

ជាទូទៅគេដឹងថាក្នុងការសិក្សា ឬការស្រាវជ្រាវស្វែងយល់លើចំណេះដឹងផ្នែកវិទ្យាសាស្ត្រ តែងតែមានការចែកចេញជាពីរយ៉ាងធំៗគឺៈវិទ្យាសាស្ត្រពិត និងវិទ្យាសាស្ត្រសង្គម ។នៅក្នុងមេរៀនដែលគ្រូបង្រៀនសិស្សមានពាក់ព័ន្ធលើវិទ្យាសាស្ត្រទាំងពីរនេះដែរប៉ុន្តែជារួមគឺគ្រូបង្រៀនមានតួនាទី ជាអ្នកសម្របសម្រួលដល់ការរៀនរបស់សិស្ស។មុននឹងធ្វើការស្រាយបំភ្លឺអំពីបញ្ហាសម្របសម្រួលនោះ យើងគប្បីយល់ថា អ្វីទៅដែលហៅថា វិទ្យាសាស្ត្រពិត និងអ្វីទៅដែលជាវិទ្យាសាស្ត្រសង្គម?

១. **<u>អំពីវិទ្យាសាស្ត្រពិតៈ</u>** គឺជាវិទ្យាសាស្ត្របានកំណត់ទៅលើមេរៀនដែលមានចម្លើយតែមួយគត់។ប៉ុន្តែបើមានចម្លើយផ្សេងពីចម្លើយដែលសន្មតថាត្រឹមត្រូវនោះគឺមិនមានទេ។ឧទាហរណ៍ៈ មេលេខ ពីរ ពីរដងគឺមានចម្លើយបួន។កាលណាមានចម្លើយខុសពីបួននេះប្រាកដជាខុស។គ្រូបង្រៀនគណិតវិទ្យា រូបវិទ្យា គីមីវិទ្យា និងវិទ្យាសាស្ត្រអនុវត្ត ឬជីវវិទ្យា ទាំងអស់នេះជាវិទ្យាសាស្ត្រពិត ពីព្រោះគេមិនអាចរកឃើញចម្លើយច្រើនលើសពីមួយនោះទេ។ចំពោះវិធីធ្វើឬរបៀបធ្វើវាមានលក្ខណៈផ្សេងគ្នាមែនតែចម្លើយតែងមានការឯកភាពគ្នាតែមួយ។នេះហើយដែលជាខ្លឹមសារបង្ហាញថា ជាវិទ្យាសាស្ត្រពិត។

២. **<u>អំពីវិទ្យាសាស្ត្រសង្គមៈ</u>** គឺជាចំណេះដឹងកើតតាមមូលដ្ឋាននៃគំនិតដែលយល់ឃើញប្លែកៗតាមសង្គមនិងនៅតាមសម័យកាលនីមួយៗព្រមទាំងទៅតាមបុគ្គលម្នាក់ៗដែលមានមូលដ្ឋានប្រវត្តិសាស្ត្រ មូលដ្ឋានភូមិសាស្ត្រ និងមូលដ្ឋានធនធានទ្រទ្រង់ប្លែកៗគ្នា។ តើវិទ្យាសាស្ត្រសង្គមបង្ហាញយ៉ាងណាខ្លះ? វិទ្យាសាស្ត្រសង្គមបានបង្ហាញអំពីចំណេះប្រាជ្ញារបស់មនុស្សតាមរយៈការច្នៃប្រឌិត

គំនិតផ្ដើមបង្កើតចេញជារូបរាងសម្រាប់ប្រើប្រាស់ និងការអប់រំដែលចាត់ទុកជាសម្បត្តិវប្បធម៌នៅក្នុងសង្គម។ឧទាហរណ៍មរតកវប្បធម៌នៃសាសនាក៏ជាវិទ្យាសាស្ត្រសង្គមដែរ។បានសេចក្ដីថា សាសនានីមួយៗតែងមានវិធានការអប់រំមិនដូចគ្នាទេជាក់ស្ដែងព្រះពុទ្ធសាសនាព្រហ្មញ្ញសាសនា គ្រិស្តសាសនា ឥស្លាមសាសនា។ល។ តែងមានឧត្តមគតិនៃមេសាសនារបស់ខ្លួនរៀងខ្លួនមិនដូចគ្នាប៉ុន្តែមានបំណងដូចគ្នាគឺចង់បានសេចក្ដីសុខដល់សាសនិកជាអ្នកកាន់តាម។ដោយឡែកចំពោះការច្នៃប្រឌិតទាំងសម្ភារៈប្រើប្រាស់ និងការបង្កើតថ្មី ព្រមទាំងការបញ្ចេញយោបល់របស់មនុស្សសុទ្ធតែមានលក្ខណៈខុសគ្នា។ទាំងអស់នេះ គឺឋិតនៅក្នុងមូលដ្ឋាននៃវិទ្យាសាស្ត្រសង្គមដែលគេទទួលស្គាល់ថា វាតែងកើតមានជារឿងធម្មតារបស់មនុស្ស។

បន្ទាប់ទៅនេះយើងឈានចូលដល់ការសម្របសម្រួលរបស់គ្រូបង្រៀនដោយមិនមែនបង្ខិតបង្ខំសិស្សឲ្យធ្វើតាមខ្លួននោះទេ។បានសេចក្ដីថា ខួរក្បាលសិស្សមិនមែនជាកញ្ច្រែងសម្រាប់ត្រងកាកគំនិតដែលគេខ្ជាក់ពីមាត់ ឬ ដូចជាកញ្ច្រែងសម្រាប់ដាក់កាកអំពៅនោះឡើយ។គ្រូបង្រៀនជាអ្នកមានភារកិច្ចកែលម្អ និងសម្របសម្រួលយោបល់សិស្សទុកសម្រាប់ឲ្យសិស្ស ដើម្បីប្រើប្រាស់តាមរយៈខ្លឹមសារមេរៀន។

ជាធម្មតាយោបល់របស់សិស្សម្នាក់ៗតែងមានលក្ខណៈខុសៗគ្នា។ប៉ុន្តែក្នុងបំណងឆ្ពោះទៅរកទិសដៅតែមួយដូចគ្នា។ឧទាហរណ៍គេធ្វើដំណើរទៅឲ្យដល់គោលដៅ ដូចជាទៅភ្នំពេញគឺអ្នកណាទៅតាមផ្លូវជាតិលេខប៉ុន្មានក៏បាន ប៉ុន្តែទៅដល់ភ្នំពេញដូចៗគ្នា។គេធ្វើការប្រៀបប្រដូចនឹងអ្នកធ្វើការរកស៊ីតែងចង់បានលុយ ដោយគេខំធ្វើការតាមមុខជំនាញប្លែកៗគ្នាយ៉ាងនោះដែរ។ ដូចនេះចំពោះចម្លើយរបស់សិស្សពុំមានអ្វីដែលខុសទាំងអស់នោះទេ ហើយក៏ពុំមែនត្រូវទាំងអស់នោះទេ គឺគ្រូគ្រាន់តែជាអ្នកសម្របសម្រួលប្រមូលមកបញ្ចូលគ្នា ដើម្បីស្ថាបនាចម្លើយមួយឲ្យបានត្រឹមត្រូវប៉ុណ្ណោះ។

ប៉ុន្តែចំពោះគ្រូបង្រៀនដែលជាអ្នកសម្របសម្រួលល្អ តែងប្រមូលយកតែចំណុចល្អរបស់សិស្សជាតម្រូវការក្នុងមេរៀន ហើយមានការសរសើរលើកទឹកចិត្តសិស្ស ដើម្បីឲ្យសិស្សកាន់តែបន្តខិតខំរៀនសូត្របានកាន់តែខ្លាំងថែមទៀត។ទន្ទឹមនេះដែរបង្រៀនមិនត្រូវបដិសេធយោបល់សិស្សដោយការវាយតម្លៃដាច់អហំការថាខុសទាំងស្រុងនោះទេចំពោះវិទ្យាសាស្ត្រសង្គមនោះ។ព្រោះបើគ្រូបង្រៀនប្រើប្រាស់ពាក្យសំដីតាមរយៈការវាយតម្លៃបែបនេះវានាំឲ្យសិស្សបាត់បង់ការច្នៃប្រឌិត និងបាត់បង់ការស្វែងរកតាមគំនិតផ្ទាល់ខ្លួន ដោយធ្វើខ្លួនឲ្យដូចសត្វសេកគ្រាប់តាមគេចាំតែមាត់ឬគ្រាន់តែជាគ្រឿងម៉ាស៊ីន សម្រាប់គេចុចប្រើ ឬដូចជាទីងមោងប៉ុណ្ណោះ៕

**លោក លី ហាក់សេង**
អតីតអធិការបឋមសិក្សាខេត្តតាកែវ
(និវត្តន៍ជន)

# ចរិត កុមារ

## ១. សេចក្ដីផ្ដើម:

ខ្ញុំមិនមែនជាអ្នកជំនាញខាងចិត្តវិទ្យាទេ តែខ្ញុំបានសិក្សាខ្លះៗអំពីវិជ្ជានេះនៅពេលដែលបានរៀននៅសាលារៀនបណ្ដុះបណ្ដាលនានា។នៅឆ្នាំសិក្សា១៩៦៣-៦៤និង១៩៦៤-៦៥ ខ្ញុំជាគរុសិស្សនៅមណ្ឌលបង្រៀនគរុវិជ្ជាកំពង់កន្ទួត។ មុខវិជ្ជាចិត្តវិទ្យាត្រូវបានបង្រៀនពីរម៉ោងក្នុងមួយសប្ដាហ៍។ សាស្ត្រាចារ្យដែលបង្រៀនចិត្តវិទ្យាថ្នាក់ខ្ញុំនោះ គឺលោក ហ៊ូ តុងហ៊ួ។ លោកជាអធិការបឋមសិក្សាដ៏មានកេរ្តិ៍ឈ្មោះមួយរូបក្នុងជំនាន់នោះ។នៅឆ្នាំសិក្សា១៩៦៩-៧០ ខ្ញុំបានសិក្សាមុខវិជ្ជានេះម្ដងទៀតនៅពេលដែលខ្ញុំជានិស្សិតសាស្ត្រាចារ្យនៅមហាវិទ្យាល័យគរុកោសល្យ។សាស្ត្រាចារ្យរបស់ខ្ញុំពេលនោះគឺអ្នកស្រី ឈាងស៊ុន សាអូន។ អ្នកស្រីជាជនជាតិបារាំងដែលមានស្វាមីជាជនជាតិខ្មែរ។ នៅឆ្នាំសិក្សា១៩៧១-៧២ខ្ញុំមានឱកាសបានសិក្សាមុខវិជ្ជានេះម្ដងទៀតនៅពេលដែលខ្ញុំបានប្រឡងជាប់ជាសិស្សសាលាគរុវិជ្ជាជាន់ខ្ពស់នៅភ្នំពេញ។ការសិក្សាខាងលើបានផ្ដល់ឲ្យនូវចំណេះដឹងមូលដ្ឋានខ្លះលើមុខវិជ្ជាដ៏លំបាកនេះ។ក្នុងពេលបំពេញការងារជាគ្រូបង្រៀន ខ្ញុំបានយកចិត្តទុកដាក់អាន ខំរៀនបន្ថែម ព្រោះយល់ថាជាគ្រូបង្រៀនត្រូវយល់ឲ្យបានច្បាស់អំពីចិត្តវិទ្យា ជាពិសេស ចិត្តវិទ្យារបស់កុមារនិងវ័យជំទង់។ ការខិតខំនេះបានជួយឲ្យខ្ញុំយល់ដឹងបានបង្គួរ តែនឹងថាឲ្យបានច្បាស់លាស់ដូចអ្នកដែលបានសិក្សាជ្រៅជ្រះនោះ មិនបានទេ។

ការអធិប្បាយរបស់ខ្ញុំខាងក្រោមនេះគឺជាគំនិតដកស្រង់ពីនេះបន្តិច ពីនោះបន្តិចមកផ្សំផ្គុំគ្នា នឹងថាជាគំនិតរបស់ខ្ញុំក៏មិនបាន។ ដោយហេតុនេះ អត្ថបទនេះពិតជាមិនបានតុបតែងពីរោះពិសាគួរឲ្យជក់ចិត្តចង់អានឡើយ។ ក្នុងករណីនេះ សូមមិត្តអ្នកអានមេត្តាយោគយល់ កន្លែងណាខុសក៏សូមកាត់ចោល កន្លែងណាមិនពីរោះក៏សូមរំលង កន្លែងណាសមរម្យអាចយកបាន ក៏សុំទទួលយកតាមការគួរ។

## ២.មូលដ្ឋាននៃចរិតរបស់កុមារ

កុមារទាំងឡាយមានចរិតលក្ខណៈខុសៗគ្នា។ខ្លះចិត្តស្រាលឆាប់ខឹង ខ្លះងរង៉ក់ ខ្លះខ្លាចគេ ខ្លះរឹងពិបាកនិយាយ ខ្លះចូលចិត្តរករឿងគេ ...។មនុស្សចាស់តែងស្ដីបន្ទោសករណីនេះថា ជាលក្ខណៈពីកំណើត ឬ លក្ខណៈសួពូជ។ " កូននេះចិត្តស្រាលដូចឪវា" មនុស្សខ្លះតែងពោលដូច្នេះសំដៅទៅកុមារដែលឆាប់ខឹង ខ្លះទៀតហាមឃាត់កូនកុំឲ្យសេពគប់ជាមួយកុមារខ្លះដែលគាត់យល់ថាជា "ពូជឃោរឃៅ"។ កុមារពិតជាអាចមានចរិតដូចឪពុកឬម្ដាយព្រោះវារស់នៅជាមួយគាត់ តែចរិតរបស់កុមារពិតជាមិនមែនមកពី "ពូជ" ទេ។

ចិត្តវិទូបារាំងម្នាក់ឈ្មោះ ហ្សង់ហ្សាក់រូស្សូ (Jean Jacques Rousseau) បានពោលថាមនុស្សកើតមកល្អជាទេ តែគឺសង្គមទេដែលធ្វើឲ្យក្លាយជាមនុស្សខូច (L' homme est né bon mais la

société le corrompt)។ ការពិតអាចដូច្នេះ ទារកដែលកើតមកមិនស្គាល់អង្រឹងទេ តែដោយម្ដាយដាក់ឲ្យវាដេកអង្រឹងរាល់ថ្ងៃ វាក៏ស្រែកយំមិនព្រមដេកនៅពេលណាដែលគ្មានអង្រឹង។ក្មេងកើតមកមិនចេះដើរទេតែដល់ឮមនុស្សចាស់ដើរគ្នារាល់ថ្ងៃវាក៏ចេះដើរដែរ។ អន្តរសកម្មភាពរាល់ថ្ងៃរវាងម្ដាយឪពុកនឹងកូនគឺជាមូលដ្ឋាននៃការឧប្បត្តិកឡើងនូវចរិតរបស់កុមារ។ ការមិនយល់នូវទំនាក់ទំនងនេះគឺជាប្រភពនៃទំនាស់ រវាងមនុស្សចាស់និងកុមារ ទំនាស់ដែលក្នុងនោះ ភាគីនីមួយៗបញ្ចេញប្រតិកម្មតាមបែបរបស់ខ្លួន។ ឪពុក ម្ដាយអាងខ្លួនឯងចាស់ តែងប្រើវិន័យនិងអំណាចបង្ខំឲ្យកូនធ្វើតាម។ ឯកូនវិញខ្លះបញ្ចេញប្រតិកម្មប្រឆាំងតបក្នុងកំហឹង បង្កនូវភាពក្ដៅក្រហាយកាន់តែខ្លាំងពីសំណាក់ម្ដាយឪពុកដែលមិនសម្របសម្រួលរឹតតែពង្រឹងអំណាចនិងបន្ថែម វិន័យ។ ចំណែកឯភាគីកូនក៏ខំពង្រឹងជំហរបន្ថែមដោយ រកហេតុផលមកសំអាង ម្ល៉ោះហើយទំនាស់នេះក៏ក្លាយជាច្រវាក់ហេតុនិងផលជាច្រវាក់ទំនាស់ដែលមិនមានទីបញ្ចប់ ហើយក៏ច្រាលទៅក្នុងអញ្ញាណ ហើយនៅទីបំផុតក៏បញ្ចេញមកក្រៅជាចរិតរបស់គេ។ វាក៏មាននូវករណីដែលកូនខ្លាចម្ដាយឪពុក មិនតបត បញ្ចេញប្រតិកម្មតាមបែបអកម្ម លេបទុកគំនិតប្រឆាំងខ្ទរមុខ ធ្វើជាកូនល្អ ស្ដាប់បង្គាប់ តែបេះដូងគេពោរពេញដោយការខកចិត្ត ការសោកស្ដាយ លាយឡំដោយកំហឹងដែលគ្មានឱកាសនឹងបញ្ចេញ។ កំហាកចិត្តនេះកប់ជ្រៅក្នុងបេះដូងរបស់កុមារ ច្រាលចូលទៅក្នុង អញ្ញាណហើយបញ្ចេញមកក្រៅជាចរិតមួយខុសពីចរិតរបស់កុមារខាង ដើម។

ដើម្បីបានយល់កាន់តែច្បាស់នូវករណីនេះ ខ្ញុំសូមជូនឧទាហរណ៍មួយគឺ ប្ដីប្រពន្ធមួយគូមានកូនប្រុសម្នាក់។ គេទាំងពីរស្រឡាញ់កូន ទៅដើរលេង មើលកុន មើលល្ខោនតែងយកកូនតាម។ ឯកូនវិញក៏ស្រឡាញ់ម្ដាយឪពុកណាស់ដែរ គេសប្បាយរីករាយពេលបានទៅណាមកណាជាមួយគាត់។ ប៉ុន្តែ នៅពេលដែលគេចម្រើនវ័យ រាងកាយលូតលាស់ ខួរក្បាលរីកចម្រើន ផ្លូវចិត្តមានការវិវត្ត។ គេលែងមើលឃើញខ្លួនជាមនុស្សតូចដែលត្រូវការថ្នាក់ថ្នម ការបបោសអង្អែលពីម្ដាយឪពុកទៀតហើយ តែជាមនុស្សធំម្នាក់អាចធ្វើអ្វីក៏បានដូចមនុស្សធំ។ គឺជាដំណាក់កាល ដែលកុមារគិតថាគេមានអត្តិភាពជាមនុស្សម្នាក់ដូចមនុស្សនានាដទៃទៀត (affirmation du moi)។ ម្ដងនេះ កុមារលែងចង់ដើរលេងជាមួយម្ដាយឪពុកទៀតហើយព្រោះដើរជាមួយគាត់ គេនៅតែជាក្មេងដែលស្ថិតនៅក្នុងឱវាទ គ្មានអ្នកណាមើលគេឃើញ។ គេចង់ដើរជាមួយពួកម៉ាកគេដើម្បីបង្ហាញ ថាគេធំហើយគេជាមនុស្សម្នាក់ដូចគេដូចឯង។ម្ដងនេះពេលម្ដាយឪពុកបបួលទៅជាមួយ គេឆ្លើយថាទេ ហើយប្រកែកដោយលើកហេតុផលមកបង្ហាញថាយ៉ាងនេះយ៉ាងនោះ...ម្ដាយឪពុកដែលមិនយល់ក៏ប្រកាន់ថា កូនព្រហើន លែងស្ដាប់បង្គាប់ ក៏ប្រើអំណាចបង្ខំ យកឈ្នះ។ កូនខ្លះបង្ខំចិត្តធ្វើតាម ទាំងមិនពេញចិត្ត ទាំងទឹកភ្នែក ខ្លះទៀតប្រកែកដាច់អហង្ការ មិនទៅជាមួយ ហើយម្ដាយឪពុកក៏ប្រើអំណាច ប្រើ វិន័យហើយទំនាស់ក៏រីកប្រទាក់ប្រទងគ្នាជារង្វិលបិទគ្មានដំណោះស្រាយ។

ទាំងនេះជាការយល់ខុសក្នុងការអប់រំ។ ជាឥរិយាបថខុសឆ្គងនៃម្ដាយឪពុកដែលបណ្ដាលឲ្យមាន វិបត្តិប្រេមការ (choc affectif) ដែលនាំដល់វិបត្តិនៃចរិតរួចក៏កើតមាននូវរបស់ដែលគេ ហៅថាកុមារពិបាកអប់រំ (enfant difficile)។ បានន័យថា អាកប្បកិរិយាខ្លះរបស់កូនដែលម្ដាយឪពុកមើលឃើញពីដំបូងថាពិបាក ទាល់គំនិតក្នុង "ការអប់រំ" នោះគឺជាដំណាក់កាលធម្មតាមួយនៃវិបត្តិចរិត។ វិបត្តិនេះនឹងត្រូវបានដោះស្រាយឬមិនបាន អាស្រ័យដោយវិធីធ្វើប្រតិកម្មរបស់ម្ដាយឪពុក។

កុមារមិនបាននាំមកជាមួយនូវចរិតល្អឬអាក្រក់ទេ។ចរិតល្អឬអាក្រក់របស់កុមារនឹងរីកចម្រើនឬវិនាសទៅអាស្រ័យដោយប្រតិកម្មនៃសង្គមជុំវិញកុមារ។នៅចំពោះមុខអាកប្បកិរិយារបស់

"កុមារ" ដែលហៅថាពិបាកអប់រំ (Enfant difficile) " នោះ យើងជាមនុស្សចាស់ត្រូវខិតខំធ្វើការសិក្សាស្វែងយល់ដោយស្ងៀមស្ងាត់និងប្រកបដោយវត្ថុវិស័យភាព រាវរកឬសគល់របស់វា រួចហើយធ្វើប្រតិកម្មក្នុងភាពទន់ភ្លន់ អនុគ្រោះ និង យោគយល់។ និយាយរួម កុមារមិនបានដឹងអ្វី និងមិនបានចូលរួមក្នុងការខ្វែងគំនិតយើងទេ។ ពួកគេគ្រាន់តែជាអ្នកដែលត្រូវរងគ្រោះនូវកំហុសដែលមិនបានប្រព្រឹត្ត។ គឺយើងជាម្ដាយឪពុកដែលត្រូវជ្រើសរើសផ្លូវត្រូវដើរ។ ម្ដាយ និងឪពុកគឺជាអ្នកដែលមាន ឥទ្ធិពលផ្ទាល់ដល់កុមារ។អ្នកទាំងពីរគប្បីផ្លាស់ប្ដូរយោបល់គ្នាស្វែងយល់អំពីកូនក្នុងភាពវត្ថុវិស័យ។ ក្នុងឧទាហរណ៍ខាងលើ ចំពោះមុខការប្រឆាំងជំទាស់របស់កូន ប្រសិនបើម្ដាយឪពុកងាកមកស្វែងយល់ពីកូនរួចប្រកាន់ឥរិយាបថទន់ភ្លន់ជាមួយគេ នោះទំនាស់អាចនឹងត្រូវបានដោះស្រាយហើយផលវិបាកពិតជាមិនអាក្រក់ឡើយ។ប៉ុន្តែការស្វែងយល់កូនពិតជាការលំបាកចំពោះម្ដាយឪពុកជាទូទៅក្នុងករណីនេះគេត្រូវស្វែងយល់រកពិគ្រោះយោបល់ជាមួយអ្នកជំនាញខាងចិត្តវិទ្យា (ប្រសិនបើមាន) គ្រូបង្រៀនដែលមានបទពិសោធន៍ឬចាស់ទុំដែលមានស្នាដៃទូន្មានកូន។

អ្វីដែលជាគ្រោះថ្នាក់គួរយកចិត្តទុកដាក់គឺ "សភាវគតិ" របស់ម្ដាយឪពុកដែលចង់ផ្ដល់ឲ្យកូននូវការអប់រំល្អ (bonne éducation) "ទទួលនូវការអប់រំល្អ"។ ការអប់រំជំនាន់បុរាណឲ្យតម្លៃការអប់រំមនុស្សដោយវិធីតឹងតែងប្រើអំណាចប្រៀបដូចជា"ការផ្សាំងសត្វ"មានចំណុចខ្វះខាតគួរឲ្យ ចៀសវាង។ ក្រោយមកក៏លេចចេញនូវគោលការណ៍នៃ "ការអប់រំសេរី" ដែលត្រូវបានប្រកាន់យកដោយអ្នកអប់រំជាច្រើននោះក៏បង្ហាញនូវភាពខ្វះខាតនិងគ្រោះថ្នាក់ជាច្រើនដែរ។ យើងជាម្ដាយឪពុកត្រូវប្រកាន់យកផ្លូវកណ្ដាលមួយដ៏ត្រឹមត្រូវ ជាផ្លូវនៃការអប់រំប្រកបដោយសមតា ដែលអាចឲ្យជៀសផុតពីភាពទន់ខ្សោយ នៃឪពុកម្ដាយសម័យបុរាណដែលនិយម ការអប់រំដោយប្រើអំណាច នឹងភាពមានះនៃម្ដាយឪពុកសម័យថ្មីដែលប្រកាន់យក "ការអប់រំសេរី"៕

**លោក អ៊ុំ សារ៉ាក់**
អតីតសិស្សសាលាគរុវិជ្ជាជាន់ខ្ពស់

## <u>រដូវភ្ជុំបិណ្ឌ</u>

| | | |
|---|---|---|
| រដូវបុណ្យភ្ជុំ | នៅវត្តចាស់ទុំ | ជួបជុំសន្តាន |
| បុណ្យធំដូនតា | ចារពីបុរាណ | ខេមរាគ្រប់ប្រាណ |
| | បានចងចាំជាក់។ | |
| មួយឆ្នាំមានម្ដង | ប្រជាត្រេសង | ឆ្លងទឹកជ្រៅរាក់ |
| ចំណីនំនែក | ទូលរែកហ៊ឹកហ៊ាក់ | បេះដូងជំពាក់ |
| | ទាក់ជាប់ចិត្តខ្មែរ ។ | |
| ស្រែបុណ្យខំសាប | បោះបង់ស្រែបាប | ដុនដាបហួរហែ |
| បញ្ជូនកុសល | ដល់ញាតិពុកម៉ែ | ទុក្ខសោកឥតល្ហែ |
| | ព្រោះតែផលកម្ម ។ | |
| ទៅវត្តនឹងបង | អូនខំផ្សំផ្សង | ចារចងចំណាំ |
| ញាតិញោមទម្លាប់ | ជាប់ជាប្រចាំ | សាបព្រោះដុះដាំ |
| | ផ្សាំផ្សាយស្រែបុណ្យ ៕ | |

**ចាប ពួក**




# អំពីសិលាចារឹកនៃប្រទេសកម្ពុជា (ត)

ក្រៅពីការបោះពុម្ពផ្សាយដូចបានពណ៌នាខាងលើសិលាចារឹកកម្ពុជាបានទទួលការបោះពុម្ពផ្សាយដ៏សំខាន់ៗនៅក្នុងសៀវភៅដូចតទៅ ៖

១."សិលាចារឹកកម្ពុជា បោះពុម្ពផ្សាយក្រោមការឧបត្ថម្ភរបស់បណ្ឌិត្យសភាសិលាចារឹក និងអក្សរសាស្ត្រ" ប៉ារីស .គ.ស. ១៩២៦។ទាំងអស់គឺមាន៦ ភាគ ដែលនៅក្នុងនោះមានផ្ទាំងនិងរូបថតសិលាចារឹកដើមចំនួន២៨៧។គឺជាឯកសារសិលាចារឹកដើមដ៏សំខាន់ដែលគេអាចធ្វើការសិក្សាប្រវត្តិនៃអក្សរខ្មែរសម័យអង្គរ និងក្រោយអង្គរ។ (Inscriptions du Cambodge, publiées sous les auspices de l'Académie des inscriptions et Belles Lettres. Paris 1926-1937: 6 tomes )។

២."សិលាចារឹកកម្ពុជា"បោះពុម្ពដោយសាលាបារាំងចុងបូព៌ា ប៉ារីស ហាណូយគ.ស១៩៣៧-១៩៦៦។ទាំងអស់គឺមានសៀវភៅ៨ភាគ។គឺជាកម្រងសិលាចារឹកជាភាសាខ្មែរនិងសំស្ក្រឹតសរសេរជាអក្សរឡាតាំង( translittération indianiste ) ដែលមានការបកប្រែ និងអត្ថាធិប្បាយជាភាសាបារាំងដោយលោក ហ្សក សឺដេស។នៅក្នុងសៀវភៅភាគទី ៨ មានបទានុក្រមនៃនរនាម ទេវនាម ស្ថាននាមព្រមទាំងបញ្ជិកាទូទៅនៃសិលាចារឹកកម្ពុជា។(G.Coedes. "Inscriptions du Cambodge", publiées par l'Ecole Française d'Extrême-Orient, Paris, Hanoi. 1937-1966) : 8 tomes ។

៣. "សិលាចារឹកកម្ពុជា" កាល់កុត្តា (ឥណ្ឌា) គ.ស ១៩៥៣។ គឺជាកម្រងអត្ថបទសិលាចារឹកភាសាសំស្ក្រឹត បោះពុម្ពផ្សាយតាមអក្សរទេវនាគរីទំនើបដោយសាស្ត្រាចារ្យ ម៉ាស៊ុំដារ។គ្មានការបកប្រែ ប៉ុន្តែមានអត្ថាធិប្បាយចំពោះសិលាចារឹកសំខាន់ៗ។ ( Majumdar R.C Inscriptions of Kambuja. Calcutta 1953) ។ សិលាចារឹកទាំងឡាយបោះពុម្ពផ្សាយទាំងបីបែបខាងលើអាចចាត់ទុកបានថាជាប្រភពឯកសារសិលាចារឹកដ៏សំខាន់មួយសំរាប់សិក្សាស្រាវជ្រាវវប្បធម៌និងអរិយធម៌

ខ្មែរបុរាណ។ ប៉ុន្តែគំនរឯកសារសិលាចារឹកម្យ៉ាងទៀត ដែលជាឯកសារដើម ហើយពុំទាន់ទទួលការបោះពុម្ពផ្សាយគឺស្ថិតនៅក្នុងបណ្ណាល័យរបស់សាលាបារាំងចុងបូព៌ា និងនៅបណ្ណាល័យជាតិទីក្រុងប៉ារីសនៃប្រទេសបារាំងតែប៉ុណ្ណោះ។នៅបណ្ណាល័យសាលាបារាំងចុងបូព៌ា នៅទីក្រុងប៉ារីសមានអត្ថបទដើម (estampages ) នៃសិលាចារឹកកម្ពុជានាសម័យអង្គរ សម័យក្រោយអង្គរសឹងគ្រប់សព្វទាំងអស់។

អំពីខ្លឹមសារនៃសិលាចារឹកជាភាសាសំស្ក្រឹត និងជាភាសាខ្មែរគឺមានក្នុងអត្ថាធិប្បាយដូចតទៅ។ សិលាចារឹកជាភាសាសំស្ក្រឹត មានចំនួនទាំងអស់៥០៣ អត្ថបទ ( តាមការបូកសរុបរបស់លោក ហ្វីលីប-ហ្សេន្នែរ )។ជាសិលាចារឹកសរសេរឡើងជាកំណាព្យ( កាវ្យ )ហើយជាទូទៅមានការពណ៌នាអំពីស្ថាបនកម្មខាងសាសនា ( ព្រហ្មញ្ញសាសនា និងពុទ្ធសាសនា ) ជារឿយៗ សិលាចារឹកជាភាសាសំស្ក្រឹតចាប់ផ្ដើមប្រារព្ធដោយការបួងសួងដល់ទេវមួយអង្គឬច្រើនអង្គនៃព្រហ្មញ្ញសាសនាតាមកំណាព្យកាព្យឃ្លោងពោរពេញដោយទស្សនៈទេវនិយមនិងទស្សនវិជ្ជាស្រង់ចេញមកពីគម្ពីរ-វេទតាមកំណាព្យស្តុតិ សរសើរដល់ព្រះមហាក្សត្រសោយរាជ្យដោយរៀបរាប់អំពីប្រវត្តិនៃរាជវង្សា-នុវង្ស អំពីបុព្វកិច្ចនៅក្នុងសមរភូមិប្រឆាំងពួកខ្មាំងសត្រូវពីប្រទេសជិតខាងអំពីការកោតសរសើរដល់ព្រះកិត្តិនាមនិងប្រាជ្ញាល្បីខ្ទរខ្ទារដល់សម័យកាលនៃរាជសម្បត្តិដែលបានផ្ដល់ភាពចម្រើនរុង-រឿង និងមហិទ្ធិឫទ្ធិដល់ព្រះមហានគរកម្ពុជទេស។មានកំណាព្យខ្លះ ពណ៌នាសរសើរដល់ឥស្សរជនជាន់ខ្ពស់ជាបព្វជិតឬជាគ្រហស្ថ ដែលមានសន្តានចិត្តជ្រះថ្លាចំពោះសាសនា ដោយការកសាងប្រាសាទ វត្តអារាម ស្រុកភូមិ សួនឧទ្យាន បារាយណ៍ និងទំនប់ទឹក។ ភាគច្រើននៃសិលាចារឹកពណ៌នាបញ្ជាក់អំពីនាមស្ថាបនករ ព្រះវិហារ រូបបដិមា ព្រមទាំងកាលបរិច្ឆេទនៃស្ថាបនកម្ម។ កំណាព្យខ្លះទៀតរៀបរាប់ព្រឹត្តិការណ៍តាមបែបប្រវត្តិសាស្ត្រ ស្តីអំពីការប្រយុទ្ធស្លាប់រស់ រវាងមេទ័ពប្រឆាំងនឹងមេទ័ពមានភក្តីភាពចំពោះរាជានិយម។ មានកំណាព្យប្រកបដោយសោកនាដ្យកម្មដែលនិពន្ធដោយព្រះនាងឥន្ទ្រទេវី ស្តីអំពីពិធីបួងសួងធ្វើភាវនាធមិជារៀងរាល់ថ្ងៃពីសំណាក់ព្រះនាងជយរាជទេវី ដើម្បីជ័យជំនះរបស់ព្រះស្វាមី គឺព្រះបាទជ័យវរ្ម័នទី៧ ដែលធ្វើចម្បាំងប្រឆាំងប្រទេសចម្ប៉ា។ មានអត្ថបទកំណាព្យពីរដ៏វែងមួយគឺសិលាចារឹកបក្សីចាំក្រុងដែលនិទានអំពីព្រំប្រទល់កម្ពុជទេសសម័យអង្គរ ( ខាងបូព៌ាទល់នឹងប្រទេសចម្ប៉ា ខាងបស្ចិមទល់នឹងប្រទេសភូមា ខាងឧត្តរទល់នឹងប្រទេសចិន ខាងទក្សិណទល់នឹងមហាសាគរ ) និងសន្តតិវង្សព្រះបាទរាជេន្ទ្រវរ្ម័ន មួយទៀត គឺសិលាចារឹកវត្តស្រីសន្ធរដែលធ្វើអត្ថាធិប្បាយអំពីទ្រឹស្តីពុទ្ធនិយមនិងពិធីសក្ការបូជាក្នុងជំនឿលើពុទ្ធសាសនាមហាយាន។

នៅក្នុងសៀវភៅស្ដីពីការស្រាវជ្រាវវចនស័ព្ទភាសាសំស្ក្រឹត តាមសិលាចារឹកនៃប្រទេសកម្ពុជា លោកភត្តចារយ បានមានប្រសាសន៍ថា"ភាសាសំស្ក្រឹតប្រើប្រាស់ក្នុងសិលាចារឹកកម្ពុជាមានលក្ខណៈត្រឹមត្រូវល្អ" ( K. Bhattacharya, Recherches sur le vocabulaire des inscriptions sancrites du Cambodge, Paris, 1964 )។

កំណាព្យសំស្ក្រឹត តាមសិលាចារឹកបានត្រូវចងក្រងឡើងតាមរចនាប័ទ្មដ៏ខ្ពង់ខ្ពស់ គគ្រឹកគគ្រេងពោរពេញដោយពាក្យប្រៀនប្រដៅ សំនួនវោហារ បុគ្គលាធិដ្ឋាន (Paraboles) និងរូបារម្មណ៍ដ៏រស់រវើក តាមរបៀបរៀបចំចង្វាក់ចាប់ចុងចួន តាមលក្ខណៈវណ្ណពុ្យាង្គដ៏ពីរោះ។កំណាព្យជាភាសាសំស្ក្រឹត ត្រូវបានសរសេរឡើងដើម្បីសូត្រដូចធម៌ស្មូត្រ ឬ ដើម្បីច្រៀងជាបទចម្រៀងស្ដុតី កោតសរសើរដល់អាទិទេពនានា ( មានព្រះឥសូរ ព្រះពិស្ណុ ព្រះព្រហ្ម )ដល់ព្រះពុទ្ធ ព្រះពោធិសត្វ និងដល់ព្រះមហាក្សត្រ ដោយមានរបាំព្រះរាជទ្រព្យ និងក្រុមតូ្យតន្ត្រី ប្រគំកំដរជាប្រក្រតី។ប្រសិនបើយោងទៅតាមប្រភេទនៃព្រឹត្តិការណ៍ដែលចោទឡើង និងជីវប្រវត្តិ ព្រមទាំងគោរម្យងាររបស់កវីបណ្ឌិត គេអាចសន្និដ្ឋានបានថាកវីបណ្ឌិតទាំងនេះ គឺជាអ្នកប្រាជ្ញខាងភាសាសំស្ក្រឹត ដែលមានដើមកំណើតជាជនជាតិកម្ពុជា ហើយមិនមែនជាកវីមកពីប្រទេសឥណ្ឌាដូចជាពាក្យពោលរបស់លោកក្លូដហ្សាក់ឡើយ។កវីបណ្ឌិតទាំងអម្បាលម៉ាននោះ រមែងធ្វើជារាជគ្រូនៃព្រះមហាក្សត្រជាព្រាហ្មណ៍បុរោហិត ជាចតុរាចារ្យ ជាសេនាមាត្យនៅបរមរាជវាំង ហើយដែលបានរៀនសូត្រគម្ពីរវេទគម្ពីរធម៌សាស្ត្រ និតិសាស្ត្រទាំងឡាយ ខាងព្រហ្មញ្ញសាសនា ឬ គម្ពីរខាងពុទ្ធសាសនាជាភាសាសំស្ក្រឹត។ នេះជាទឡ្ហីករណ៍ដ៏សំខាន់បំផុត ដើម្បីឲ្យយើងអាចធ្វើការសន្និដ្ឋានបានថា កំណាព្យជាភាសាសំស្ក្រឹតតាមសិលាចារឹកកម្ពុជា គឺពិតជាវណ្ណកម្ម ឬនិម្មាបនកម្មនៃអក្សរសាស្ត្របុរាណនៃកម្ពុជា ពីសតវត្សទី៣(តាមសិលាចារឹកវ៉ូកាញ់ ) ឬទី៥ ដល់សតវត្ស ទី១៤ នៃគ្រិស្តសករាជ។ ពិតមែនហើយ នាសម័យបច្ចុប្បន្នគេអាចពិនិត្យឃើញថា ប្រជាជនកម្ពុជាពុំទាន់ដែលបានក្រេបជញ្ជក់នូវរសជាតិ និងសោភ័ណភាពដ៏ស្រស់បំព្រងនៃអក្សរសាស្ត្របុរាណរបស់ខ្លួនជាភាសាខ្មែរនៅឡើយដោយហេតុថាកំណាព្យសំស្ក្រឹតតាមសិលាចារឹកទាំងប៉ុន្មាន ពុំដែលបានទៅជាកម្មវត្ថុនៃការបកប្រែមកជាកំណាព្យជាភាសាជាតិនៅឡើយ។

(នៅមានត)

**បណ្ឌិត ឡុង សៀម**

វចនានុក្រមខ្មែរបុរាណ តាមសិលាចារឹកបុរេអង្គរ សតវត្សទី៦-៨

# អត្ថប្រយោជន៍នៃទិវាអំណានកម្ពុជា (ត)

## IV.អត្ថប្រយោជន៍អំណាន

មនុស្សស្ទើរតែគ្រប់គ្នាបានដឹងថាសៀវភៅ និងឯកសារផ្សេងៗគឺជាឃ្លាំងនៃចំណេះដឹងបទពិសោធន៍ ជំនាញនិងព័ត៌មានមិនចេះរីងស្ងួត។ ការអានសៀវភៅប្រៀបដូចជាការសំលៀងខួរក្បាលឱ្យមានភាពមុតស្រួច ដើម្បីផ្តល់អត្ថប្រយោជន៍ដល់ខ្លួនឯង សង្គមនិងពិភពលោកទាំងមូល។ បើសិនជាយើងមិនបានអានអ្វីសោះ អ្នកនឹងបាត់បង់ព័ត៌មាន និងមិនយល់អំពីអត្ថប្រយោជន៍នៃការអានសៀវភៅឡើយ ហើយនឹងក្លាយជាការខ្ជះខ្ជាយពេលវេលា និងមិនយល់ពីហេតុផលរបស់មនុស្សដទៃ។ការអានជួយខួរក្បាលរបស់អ្នកឲ្យមានសកម្មភាពជាប្រចាំ និងយល់នូវទស្សនៈសំបូរបែបតាមរយៈការមើលទូរទស្សន៍ស្តាប់វិទ្យុជាដើម។ សព្វថ្ងៃនេះការអានសៀវភៅជួយអ្នកឲ្យបានដឹងពីពិភពលោកកាន់តែទូលំទូលាយឡើង។

ខាងក្រោមនេះគឺជាអត្ថប្រយោជន៍នៃការអានសៀវភៅ ៖

### ១.បង្កើនសមត្ថភាពខួរក្បាល

អ្នកស្រាវជ្រាវបានរកឃើញថា ការរក្សានូវស្មារតីរឹងមាំ កាត់បន្ថយនូវភាពតានតឹងផ្នែកខួរក្បាល ឬការពារជំងឺភ្លេចភ្លាំង វង្វេងនៅក្នុងរាងកាយរបស់អ្នក។ រាងកាយរបស់មនុស្សត្រូវការចំណីអាហារ និងលំហាត់ប្រាណ ដើម្បីបន្តអត្ថិភាព និងសុខភាពល្អមិនខុសគ្នាឡើយ។ ខួរក្បាលរបស់អ្នកក៏ត្រូវការចំណីអាហារ លំហាត់ប្រាណ និងធ្វើការដើម្បីបង្កើនសមត្ថភាពសុខភាពខួរក្បាលដែលក្នុងនោះការអានគឺជាចំណីដ៏ល្អសម្រាប់ខួរក្បាល។មនុស្សអាចធ្វើការអភិវឌ្ឍប្រាជ្ញា ស្មារតីតាមរយៈវិធីច្រើនយ៉ាងក្នុងនោះអំណានក៏ជាវិធីដ៏សំខាន់មួយដែរ។

### ២.កាត់បន្ថយជំងឺថប់អារម្មណ៍ (ស្ត្រេស)

អ្នកមិនថប់អារម្មណ៍ក្នុងជីវិតប្រចាំថ្ងៃរបស់អ្នកឡើយ ប៉ុន្តែវានឹងរលុបបាត់ចេញពីខួរក្បាលរបស់អ្នកនៅពេលដែលអ្នកកំពុងតែលង់ក្នុងរឿងដ៏អណ្តែតអណ្តូងមួយ ឬប្រធានបទមួយដែលអ្នកចាប់អារម្មណ៍។ ជំងឺស្ត្រេសបានកើតឡើងចំពោះអ្នកតាមរយៈសកម្មភាពស្មុគស្មាញផ្ទាល់ខ្លួន។ ការអានបានជួយកាត់បន្ថយកម្រិតស្ត្រេសនៅកម្រិតទាបបំផុត បើធៀបជាមួយវិធីសាស្ត្រផ្សេងៗទៀត។ ការអានគឺជាវិធីដ៏ល្អបំផុត ដើម្បីសម្រួលខួរក្បាលរបស់អ្នក។ អ្នកស្រាវជ្រាវចិត្តវិទ្យាបានរកឃើញថា នៅពេលអារម្មណ៍របស់មនុស្សកំពុងផ្តោតលើការអានក្នុងពិភពអក្សរសាស្ត្រ នោះការរំខាននានា ភាពតានតឹងក្នុងសាច់ដុំ និងបេះដូងត្រូវបានកាត់បន្ថយជាបន្ត។

### ៣.បង្កើនចំណេះដឹង គំនិតច្នៃប្រឌិត និងការស្រមៃ

គេតែងតែនិយាយថា មុននឹងសរសេរសៀវភៅបានមួយក្បាលមនុស្សខ្លះអាចនឹងចំណាយពេលពេញមួយជីវិតរបស់គេ។ប៉ុន្តែសម្រាប់អ្នកអានវិញគេប្រើរយៈពេលយ៉ាងយូរមួយសប្តាហ៍ ដើម្បីក្រេបយកបទពិសោធន៍ និងចំណេះដឹងរបស់អ្នកនោះ។ តាមរយៈការអាន គំនិតច្នៃប្រឌិត

និងក្ដីស្រមៃក៏ត្រូវបានអភិវឌ្ឍ ព្រោះវាបានផ្ដល់នូវទស្សនៈនិងការយល់ដឹងខុសៗគ្នា។អ្នកពូកែអាន គឺជាអ្នកមានវ័យក្មេងហើយនឹងអាចក្លាយជាអ្នកពូកែសរសេរផងដែរ។ការអានច្រើនបានធ្វើឱ្យអ្នក មានការស្រមៃកាន់តែស៊ីជម្រៅក្នុងពិភពលោកថ្មីយើងនេះ ហើយបានជំរុញឱ្យខួរក្បាលរបស់អ្នក បង្កើតគំនិតថ្មី និងលទ្ធភាពផ្សេងៗ ដែលអាចអនុវត្តបានឆ្ពោះទៅរកការរីកចម្រើនស្របតាមបរិបទ ពិភពលោក។ការអានបានជួយអ្នកឲ្យកាន់តែប្រសើរឡើងតាមរយៈការយល់ដឹងលើប្រធានបទ ដែលអ្នកចាប់អារម្មណ៍។ ជាទូទៅសៀវភៅទាំងអស់នឹងផ្ដល់នូវការយល់ដឹង និងចំណេះដឹងកាន់តែ ច្រើនដែលអាចនិយាយបានថាចំណេះដឹងច្រើនគឺជាគន្លឹះនៃភាពជោគជ័យដែលអាចដឹកនាំជីវិត យើងកាន់តែល្អប្រសើរ។

**៤.បង្កើនចំណេះដឹងផ្នែកវាក្យសព្ទ**

វាមានសារៈសំខាន់បំផុតសម្រាប់អ្នកដែលរៀនភាសាបរទេស ព្រោះបើអ្នកអានកាន់តែច្រើន អ្នកនឹងដឹងថា អ្នកនិពន្ធបានប្រើប្រាស់នូវវាក្យស័ព្ទយ៉ាងសម្បូរបែប ដើម្បីគូសបញ្ជាក់អំពីអារម្មណ៍ មនោសញ្ចេតនានិងហេតុការណ៍ផ្សេងៗ។មនុស្សជាច្រើនបានប្រឈមជាមួយការរៀនភាសាបរ-ទេសដោយខ្វះនូវមធ្យោបាយអំណាន។ការអានច្រើនបានជួយលើកកម្ពស់ នូវគំនិត ពាក្យថ្មីវេ-យ្យាករណ៍ ឃ្លាប្រយោគ ល្បះ ដែលគេអាចនិយាយបានថា ការសិក្សាដោយខ្លួនឯង ដែលមាន បណ្ណាល័យជាឃ្លាំង និងសៀវភៅជាគ្រូ។

**៥.មានជំនាញគិត និងវិភាគស៊ីជម្រៅ**

នៅពេលខ្លះអ្នកបានអានរឿងដ៏អាថ៌កំបាំងដូចជារឿងឧក្រិដ្ឋកម្មឬស៊ើបអង្កេតជាដើម។ មុនពេលដែលអ្នកអានចប់សៀវភៅនោះ អ្នកមានចម្លើយក្នុងចិត្តរួចជាស្រេចថា រឿងនោះនឹងត្រូវ បញ្ចប់ដោយរបៀបណា។នេះហើយគឺជាសមត្ថភាពនៃការគិតបែបស៊ីជម្រៅដែលទទួលបានអំពី បទពិសោធន៍នៃការអានសៀវភៅរបស់អ្នក។ ការអានច្រើនក៏បានជួយបង្កើនបញ្ញានូវអ្វីដែលអ្នក សរសេរបានអប់រំ។តាមរយៈការអានសៀវភៅអ្នកនឹងទទួលបានបទពិសោធន៍ជីវិតតាមរយៈមនុស្ស ល្បីៗអ្នកអាចយល់ពីជីវិតដ៏អស្ចារ្យរបស់គេដើម្បីរៀបចំខ្លួនរបស់អ្នកឲ្យបានល្អក្នុងអនាគត។ការ អានច្រើនមិនអនុញ្ញាតឲ្យអ្នកមានអាកប្បកិរិយាផ្ដេសផ្ដាសបានតាមអំពើចិត្ត និងអាចធ្វើអ្វីដែលអ្នក គិតថាធ្វើកើតស្របតាមសមត្ថភាព។ (នៅមានត)

*លោក គួយ សូគាន* (NIE)

| | |
|---|---|
| កុំមើលងាយថាបញ្ញាតិច | រៀនទៅក្រែងភ្លេចមិនចម្រើន |
| សុតម័យ[1]បញ្ញាបើក្រើន | យូរទៅគង់ច្រើនពេញហឫទ័យ |
| ដូចក្អមតម្កល់លើដំបូក | ភ្លៀងធ្លាក់ជោកៗអចិន្ត្រៃយ៍ |
| តំណក់តក់ៗតែរាល់ថ្ងៃ | អាស្រ័យយូរទៅគង់ពេញបាន។ |

**គម្ពីរលោកនីតិ**

(1) ដែលកើតអំពីការស្ដាប់ ។

# អំពីនិបាតសព្ទ និង អាយតនិបាត (ត)

+ ទោះបីជា (និ. ដូចគ្នានឹងទោះជា, ទោះណាជាដែរ) គ្រាន់តែជាវចនាលង្ការ គឺនិបាតសព្ទជាអលង្ការរបស់សំដីតែប៉ុណ្ណោះ)
+ វត្តអារាម ទោះបីជាកន្លែងស្ងប់សម្រាប់អ្នកបួសសម្ងំបន្ទំចិត្ត ជម្រះកិលេសតណ្ហា កាត់ផ្ដាច់ការជាប់ជំពាក់ នឹងជីវភាពរស់នៅរបស់មនុស្សក៏ដោយ ក៏វត្តនៅតែមានទំនាក់ទំនងជាប្រចាំជាមួយនឹងសង្គម ផ្សារភ្ជាប់និងសង្គមជានិច្ចកាល។
+ មនុស្សម្នាក់ៗ ត្រូវមានជីវិតរស់នៅក្នុងសង្គមដ៏ពិតប្រាកដមួយ ទោះបីជា យើងមិនហ៊ាននិយាយថា "មនុស្សហ៊ានស្លាប់ដើម្បីទ្រព្យ" ក៏ដោយ ក៏មនុស្សដែលអាចរស់នៅបាន មិនអាចមិនគិតពីផលប្រយោជន៍របស់ខ្លួនបានឡើយ។
+ អ្នករស់នៅក្នុងទីក្រុងធ្វើការនៅតែមួយកន្លែងបរិភោគអាហារច្រើន ខ្វះការហាត់ប្រាណហើយឡើងទម្ងន់ទៀត អ្នកទាំងនោះងាយនឹងមានជំងឺទឹកនោមផ្អែមទោះបីជាគ្រួសាររបស់ពួកគេគ្មាននរណាម្នាក់កើតជំងឺទឹកនោមផ្អែមក៏ដោយ។
+ ទោះបីជា លោកអ្នកមានការមមាញឹកនឹងការងារប្រចាំថ្ងៃ យ៉ាងណាក៏ដោយ ក៏លោកអ្នកចេះប្រើពេលមួយរយៈខ្លី ដោយចំណាយពេលប្រហែលពី ១៥ ទៅ ២០ នាទីធ្វើការហាត់ប្រាណសម្រាប់ចលនាដើម្បីរាងកាយ។
+ ដើម្បីកសាងប្រទេសជាតិឲ្យបានរុងរឿងដូចសម័យអង្គរ ទោះបីជា លំបាកយ៉ាងណាក៏ដោយ ក៏យើងពេញចិត្តនឹងរួមសុខរួមទុក្ខជាមួយនឹងប្រជាពលរដ្ឋខ្មែរទូទាំងប្រទេសដែរ។
+ មនុស្សច្រើនមតិយោបល់ក៏កាន់តែច្រើន ទោះបីជាមានមតិខ្លះមិនស្របគ្នាយ៉ាងណាក៏ដោយក៏មិនគួរចាត់ទុកឲ្យខ្មែរនិងខ្មែរក្លាយជាសត្រូវស្លាប់រស់នឹងគ្នានោះទេ។
+ ទោះបីជា អាចបំពេញតាមបំណងប្រាថ្នាបានមួយរយៈហើយក្ដី ក៏នៅតែមិនអាចបំពេញបាននូវកង្វះចន្លោះឬការស្រេកឃ្លានរបស់មនុស្សបានដែរ។
+ យើងម្នាក់ៗទោះបីជា ស្ថិតនៅទីណាក៏ដោយ ក៏យើងត្រូវរក្សាសុខភាពឲ្យបានល្អប្រសើរជានិច្ច។
+ ទោះបីជា (ឬទោះជា) រៀនបានសម្រេចអ្វីមួយក៏ដោយ ក៏មិនមែនមានន័យថា អ្នកចេះអស់នោះទេ រៀនកាន់តែច្រើន កាន់តែដឹងថាខ្លួននៅចេះតិចដដែល។

ក្នុងជីវិតប្រចាំថ្ងៃ ឬក្នុងកិច្ចការរកស៊ីផ្សេងៗ ទោះបីជាផ្នែកឯកជនឬជាប្រភេទក្រុមហ៊ុនតូចធំតែងតែមានការជួបនឹងវិបត្តិ ឬការខាតបង់ដោយសារតែចំណូលតិចជាងចំណាយ។

+ ទោះបីជា យើងពុំមានចេតនារិះគន់ដោយធ្ងន់ៗក៏ដោយ តែការមិនចេះជ្រើសរើសពាក្យយកមកប្រើឲ្យបានសមរម្យ ធ្វើឲ្យសម្ដីយើងមានរបៀបទៅទាំងកាក។

+ ជីវិតរបស់មនុស្សគេចមិនផុតពីការប្រើពាក្យ "កុហក" ទោះបីជាសង្គមមានការរីកចម្រើនជឿនលឿនយ៉ាងណាក៏ដោយ ពាក្យ "កុហក" ក៏នៅតែមានគេប្រើជាប្រចាំ។
+ យើងមិនត្រូវរុញអីវ៉ាន់ដែលយើងត្រូវលក់ដោយត្រង់ៗទៅឲ្យគេនោះទេ ព្រោះនាំឲ្យគេមានមន្ទិលសង្ស័យទោះបីជារបស់យើងល្អយ៉ាងណាក៏ដោយ។
+ ទោះបីស្រុកទេសធ្លាក់ក្នុងវិបត្តិធំៗ ខ្សត់អ្នកប្រាជ្ញ ខ្សត់គម្ពីរក្បួនខ្នាត ដូចក្នុងសម័យខ្លះមានសម័យក្រុងលង្វែកជាដើម ក៏ដោយ ក៏ជនជាតិខ្មែរនៅតែរក្សាប្រពៃណី ធ្វើបុណ្យទាន ដរាបដល់សព្វថ្ងៃ។
+ ថ្ងៃនេះ ខ្ញុំត្រូវតែចេញទៅខេត្តសៀមរាបដើម្បីទស្សនា ប្រាសាទអង្គរវត្តទោះបីមានភ្លៀងធ្លាក់ខ្លាំងយ៉ាងណាក៏ដោយ។
+ ទោះបីត្រកូលណាក៏ដោយឲ្យតែចូលបួសក្នុងធម្មវិន័យរបស់ព្រះពុទ្ធ ទ្រង់ដាក់ឋានៈស្មើគ្នាទាំងអស់។
+ តាមការសិក្សាស្នាដៃអក្សរសិល្ប៍ខ្មែរ "រឿងរាមកេរ្ដិ៍"គេឃើញថា ទោះបីគេបានរក្សាទុកឈ្មោះតួអង្គ ទីកន្លែងឲ្យនៅស្រដៀងនឹងឈ្មោះដើមក៏ដោយ ក៏ប៉ុន្តែខ្លឹមសាររបស់វា មានលក្ខណៈខុសគ្នាស្រឡះពីរឿង "រាមាយណៈ" របស់ឥណ្ឌា។

សង្កេត ពាក្យ "ទោះបី" ឬ "ទោះបីជា" បើគេដាក់ពាក្យ "តែ" ឬ "ក៏ដោយ" ឬ "យ៉ាងណាក៏ដោយ បន្ថែមនោះ ឃ្លាបន្ទាប់ហាក់មានន័យផ្ទុយពីឃ្លាខាងដើម។

(នៅមានត)

*និពន្ធដោយលោក **ទិត សៀង** អតីតសាស្ត្រាចារ្យទុតិយភូមិ១៩៧២*

| ការខ្លាចនៃវត្ថុ៤យ៉ាង៖ | | ធៀបនឹងមនុស្សខ្លាច៤ពួក៖ |
|---|---|---|
| ១- ទឹកខ្លាចគេដងទុកតម្កល់ | ⟶ | អ្នកមានចំណេះ ខ្លាចគេទុកស្ងៀម |
| ២- ជាតិដែកដែកដុល ខ្លាចដំនៅ | ⟶ | អ្នកធ្វើការងារ ខ្លាចគេប្រើគ្មានថ្លៃ |
| ៣- គ្រញូង ខ្លាចធ្វើខ្ទួច កូចដូចស្មៅ | ⟶ | អ្នកជាន់ខ្ពស់ខ្លាចគេប្រើឲ្យធ្វើការទាបថោក |
| ៤- ទូកខ្លាចគេទៅជាន់គែមផ្លៀង | ⟶ | អ្នកមានរឿង ខ្លាចអ្នកដទៃមកជាសំអាង។ |

ឧកញ៉ាសុត្តន្តប្រីជាឥន្ទ




## បណ្ដាំឪពុក

### (បទពាក្យ៧)

- ឱកូនប្រុសស្រីកូនចាំស្ដាប់ ពុកនឹងរ៉ាយរ៉ាប់ប្រាប់រឿងពិត
ស្ដាប់ហើយកូនត្រូវយកគំនិត យកមករិះគិតកូនពិតដឹង ។
- ពេលនេះពុកចាស់ច្បាស់មុនកូន ជីវិតក្រាបលូនគ្មានទីពឹង
ពុកយកកម្លាំងដើម្បីប្រឹង ធ្វើជាលំនឹងដល់សព្វថ្ងៃ ។
- ពុកគ្មានវិជ្ជាគ្មានតម្រិះ ពុកគ្មានចំណេះចេះប្រស្រ័យ
ពុកយកកម្លាំងធ្វើរាល់ថ្ងៃ ព្រោះតែពុកខ្ចីខ្លីប្រាជ្ញា ។
- កូនអើយចំណេះគឺជាទ្រព្យ សែនប្រសើរគាប់ជាប់អាត្មា
គ្មានអ្វីប្រសើរជាងនេះណា កូនត្រូវសិក្សាសង្វាតរៀន ។
រៀនហើយរៀនទៀតរៀនមិនឈប់ រៀនទាំងថ្ងៃយប់កុំខ្ជាសអៀន
រៀនយកចំណេះធ្វើជាស្ពាន រៀនធ្វើមេរៀនក្នុងជីវិត ។
- គំរូឪពុកទុកឲ្យកូន មិនចេះសាបសូន្យកូនត្រូវគិត
បូកដកគុណចែកសាងជីវិត ឲ្យកូនដឹងពិតគិតមិនខាន ។
- ពេលណាកូនរៀនមានចំណេះ ពេលណាកូនចេះកូននឹងស្រាន្ត
ទ្រព្យយសមាសប្រាក់បុណ្យសក្ដិមាន នេះហើយជាស្ពានឈានដល់ត្រើយ។
- មួយទៀតកិត្តិយសឈ្មោះថ្កើងថ្កាន កូននឹងសុខសាន្តប្រាណល្ហែល្ហើយ
ចងចាំឲ្យច្បាស់ណាកូនអើយ នេះហើយគឺជាបណ្ដាំពុក ។
វិជ្ជាជាទ្រព្យគាប់ប្រសើរ នាំកូនឲ្យដើរឆ្ពោះទៅមុខ
- វិជ្ជាគឺជាស្រូវជង្រុក ឲ្យកូនដាក់ទុកកើនប្រាជ្ញា ។
គ្មានចោរឯណាមកលួចបាន នៅជាប់ក្នុងប្រាណកូនរក្សា
ទុកជាអាវុធរួមការពារ កូនគ្រប់វេលាតរៀងទៅ ។
ពុកល្ងង់ពុកល្ងើភ្លើចំណេះ ពុកគ្មានតម្រិះត្រិះរកផ្លូវ
ពុកគ្មានវិជ្ជានឹងឆ្ពោះទៅ អនាគតពុកនៅមិនខ្ពង់ខ្ពស់ ។

ដូច្នេះចូរកូនត្រូវខំប្រឹង ស្វែងរកលំនឹងកុំឡេះឡោះ
វិជ្ជាកូនរៀនឲ្យចេះអស់ អនាគតកូនរស់ឈ្មោះថ្កុំថ្កើង ។

**លោកស្រី អ៊ឹម សុផល្លី**
អនុប្រធាននាយកដ្ឋានយុវជន

ពីឆ្នាំ១៨៨៦ ឆ្នាំរកាសប្តស័ក ព.ស.២៤២៨ មកឃើញប្រើៈ យ៉ាំងវីយេ, ហ្វេវ្រីយេ, មារ្ស, អាវរីល, ម៉េ, យូវាំង, ស្វយេត, អាអ៊ូត, សេបតមប្រឹ, ឧកតូប្រឹ, ណូវមប្រឹ, ដេសមប្រឹ។

ឆ្នាំរកាឆស័ក ព.ស.២៤៨៧ គ.ស.១៩៤៥ ទើបឃើញប្រើៈ មករា, កុម្ភៈ, មីនា, មេសា, ឧសភា, មិថុនា, កក្កដា, សីហា, កញ្ញា, តុលា, វិច្ឆិកា, ធ្នូ។

អតីតប្រតិទិនបារាំង-ខ្មែរ

**ចៅ សំអាន**

## 1886 ឆ្នាំរកា សប្តស័ក ព-ស ២៤២៨ ច-ស ១២៤៧

| JANVIER យ៉ាំងវីយេ | | | FEVRIER ហ្វេវ្រីយេ | | | | MARS មារ្ស | | | | AVRIL អាវរីល | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ...សុក្រ | ១០ | ព្រាប មគសិរ | 1 | ចន្ទ | ១២ | | 1 | ចន្ទ | ១០ | | 1 | ព្រហ. | ១២ | |
| ...សៅរ៍ | ១១ | | 2 | អង្គារ | ១៣ | | 2 | អង្គារ | ១១ | | 2 | សុក្រ | ១៣ | |

| MAI ម៉េ | | | | JUIN យូវាំង | | | | JUILLET ស្វយេត | | | | AOUT អាអ៊ូត | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 1 | សៅរ៍ | ១២ | | 1 | អង្គារ | ១៤ | | 1 | ព្រហ. | ១៤ | ខែដាច់ | 1 | អាទិត្យ | ១ | កើត ខែស្រាព |
| 2 | អាទិត្យ | ១៣ | | 2 | ពុធ | ១៥ | ខែដាច់ | 2 | សុក្រ | ១ | កើត ខែអាសាធ | 2 | ចន្ទ | ២ | |

| SEPTEMBRE សេបតមប្រឹ | | | OCTOBRE ឧកតូប្រឹ | | | | NOVEMBRE ណូវមប្រឹ | | | | DECEMBRE ដេសមប្រឹ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ពុធ | ៣ | កើត ខែភទ្របទ | 1 | សុក្រ | ៣ | កើត ខែអស្សុជ | 1 | ចន្ទ | ៥ | កើត ខែកត្តិក | 1 | ពុធ | ៥ | |
| ...ហ. | ៤ | | 2 | សៅរ៍ | ៤ | | 2 | អង្គារ | ៦ | | 2 | ព្រហ. | ៦ | |
| ...សុក្រ | ៥ | | 3 | អាទិត្យ | ៥ | | 3 | ពុធ | ៧ | | 3 | សុក្រ | ៧ | |
| ...សៅរ៍ | ៦ | | 4 | ចន្ទ | ៦ | | 4 | ព្រហ. | ៨ | ថ្ងៃសិល | 4 | សៅរ៍ | ៨ | ថ្ងៃសិល |
| ...ទិត្យ | ៧ | | 5 | អង្គារ | ៧ | | 5 | សុក្រ | ៩ | | 5 | អាទិត្យ | ៩ | |
| ចន្ទ | ៨ | ថ្ងៃសិល | 6 | ពុធ | ៨ | ថ្ងៃសិល | 6 | សៅរ៍ | ១០ | | 6 | ចន្ទ | ១០ | |
| ...ង្គារ | ៩ | | 7 | ព្រហ. | ៩ | | 7 | អាទិត្យ | ១១ | | 7 | អង្គារ | ១១ | |
| ...ពុធ | ១០ | | 8 | សុក្រ | ១០ | | 8 | ចន្ទ | ១២ | | 8 | ពុធ | ១២ | |
| ...ហ. | ១១ | | 9 | សៅរ៍ | ១១ | | 9 | អង្គារ | ១៣ | | 9 | ព្រហ. | ១៣ | |
| ...សុក្រ | ១២ | | 10 | អាទិត្យ | ១២ | | 10 | ពុធ | ១៤ | អុំទូក | 10 | សុក្រ | ១៤ | |
| ...សៅរ៍ | ១៣ | | 11 | ចន្ទ | ១៣ | | 11 | ព្រហ. | ១៥ | ពេញបូរ សំពះព្រះខែ | 11 | សៅរ៍ | ១៥ | ពេញបូរ |

## កំហុសអ្នកណា ? (ត)
### (បទពាក្យប្រាំពីរ)

៣៧. អមាត្យជំនិតអង្គទេវា បានស្តាប់បញ្ហាទេវៈហើយ
ចាប់ចេញយាត្រាមិនកន្តើយ ផុតហើយហោះវឹងមកផែនដី។
៣៨. ចូលដល់កោះហៅទៅគង្គា ថាអង្គទេវាជាចមត្រៃ
ឲ្យខ្ញុំមកហៅអ្នកអង្គថ្លៃ ចូលគាល់ឆាប់ខ្មីដ្បិតមានការ។
៣៩. គង្គាឮជាក់ជាបញ្ហា នៃអង្គទេវានោះកាលណា
មិនហ៊ានប្រកែកមិនដោះសា ឆាប់ចរយាត្រាមកភ្លាមៗ។
៤០. ចូលដល់យល់ភក្ត្រញាក់ញ័រដៃ លំឱនសិរសីមិនទីមទាម
ទេវៈយល់ហើយមិននៅស្ងៀម ពោលពាក្យមកភ្លាមថានៃទឹក។
៤១. យើងបានចាត់ហៅអ្នកថ្លៃមក តើអ្នកមានភ្នកគំនិតនឹក
ថាខ្លួនមានទោសធំពន្លឹក នៃទឹកហេតុម្តេចក៏អ្នកថ្លៃ។
៤២. មានចិត្តប្រែប្រួលខុសមុនណា ម្តេចអ្នកសាវ៉ារត់ចោលដី
ដឹងទេធ្វើនោះមិនប្រពៃ ចោលគ្នាជាដីឲ្យក្រៀមក្រំ។
៤៣. គង្គាឮហើយទូលតបថា ឱអង្គទេវាជាម្ចាស់ខ្ញុំ
រឿងនេះសូមស្តេចកុំច្រឡំ រឿងដែលខុសធំនោះគឺថា។
៤៤. មកពីកម្តៅដ៏ក្តៅហែង ចាំងចែងពីព្រះអង្គសុរិយា
ដ្បិតតែប៉ុន្មានឆ្នាំនេះណា អង្គព្រះសុរិយាដូចចម្លែក។
៤៥. មិនដឹងជាលោកខឹងរឿងអី ចែងចាំងស្មើក្តៅខ្លាំងប្លែក
ក្តៅហួតក្តៅហែងក្រហែងបែក ក្តៅនោះចម្លែកប្លែកធម្មតា។
៤៦. ទាញស្រូបរូបខ្ញុំឲ្យហោះឡើង ប៉ើតប៉ើងអណ្តែតលើវេហា
ឃ្លាតកាយឆ្ងាយដីមកឯកា ឯកោកណ្តាលវាយោព្យុះ។
៤៧. ការពិតខ្ញុំគ្មានចិត្តតិចណា សាវាដូចពាក្យដែលចោទនោះ
ដូច្នេះរឿងធំរឿងដែលខុស កំហុសកើតពីព្រះសុរិយា។
៤៨. ឥស្សរបានស្តាប់សព្វគង្គា រៀបរាប់ពណ៌នាគ្រប់សព្វសារ
ងាកហៅអមាត្យមកប្រាប់ថា ចូរចរយាត្រាចេញទៅភ្លាម។
៤៩. ហៅព្រះអនុជឲ្យមកឆាប់ ប្រញាប់កុំបីនៅទីមទាម
ថាយើងឥស្សរជាព្រះរៀម ឲ្យចូលគាល់ភ្លាមដ្បិតមានការ។
៥០. អមាត្យក៏បាននាំមកដល់ យុងយល់ព្រះភក្ត្រព្រះជេដ្ឋា

ក្រាបខិនលំទោនអង្គកាយា លើកអង្គហត្ថាប្រណម្យថ្វាយ។
៥១. ទើបទូលសួរថាអង្គទេវៈ ហៅប្អូនមកជាក់ពីដែនឆ្ងាយ
តើមានការអ្វីសូមអភិប្រាយ បរិយាយឲ្យប្អូនបានដឹងផង។
៥២. ឥសូរទេវៈជាជេដ្ឋា ថាអើនែអានុជប្អូនបង
រៀមហៅប្អូនមកពេលនេះម្តង ព្រោះមានបំណងចង់ដឹងដាន។
៥៣. ដ្បិតតែពេលនេះនាងគង្គា ថាប្អូនពុំងាប្រុសកល្យាណ
បញ្ចេញកំដៅក្តៅហួសស្មាន តើពិតអូនបានខឹងរឿងអ្វី។
៥៤. សុរិយាបានស្តាប់សព្វវាចា អង្គព្រះជេដ្ឋាម្ចាស់ថ្លើមថ្លៃ
បានដឹងគ្រប់សព្វសព្វសេចក្តី ទូលតបសម្តីទៅវិញថា។

(នៅមានត)

លោក **ភិន វ៉ាន់ណា**
មន្ត្រីអធិការកិច្ចខេត្តកំពង់ចាម

## សត្វ និងរុក្ខជាតិដែលជានិមិត្តសញ្ញាតំណាងឲ្យជាតិខ្មែរ

- ស្មេរសោកល្បង ចងចែងចារ ថ្លាថ្លែងស្តី
ជាកាព្យខ្លី ស្តីតាមចាំ សាំកុំថា
រាប់រឿងសត្វ អត្តច្បាស់ ចាស់ចែងចារ
ទាំងរុក្ខា ជាអ្នកចាំ ផ្តាំចែកទៀត ។

- ផ្តើមពី**ត្នោត** ដោតដាំដុះ ច្រុះច្រូងច្រាង
ឈើតំណាង តាងនាមខ្មែរ ចែឈ្មោះជាតិ
**ផ្ការំដួល** ឆ្វលក្រអូប ស្រូបអស់ញាតិ
ផ្កាតាងជាតិ ឃ្លាតទៅឆ្ងាយ ស្តាយបុប្ផា ។

- **ចេកពងមាន់** គ្រាន់ក្រៃណា តាតាក់តែង
ចេកជាតិឯង ស្តែងអត្ត ឆ្លាក់ខេមរា
**គោព្រៃ**ម្រឹគ ទឹកមានត្រី ល្បីមច្ឆា
ប្រាប់តាមតា ថានោះអី **ត្រីគល់រាំង**។

- **អណ្តើកហ្លួង** ជួងគេគោះ គ្រោះក្រៃក្រាស់
សល់តិចណាស់ ខ្វះជម្រក ជ្រកពារពាំង
**សត្វត្រយង** ផ្សងជីវិត ជិតឆ្ងាយគាំង
ស្មុះដូចស្នាំង ទាំងភិតភ័យ ព្រៃប្រួលប្រែ ៕

ប៉ាកកាខ្មៅ



# ចរិតខ្មែរ

## <u>សេចក្ដីផ្ដើម</u>

ប្រទេសជាតិនីមួយៗតែងមានអត្តសញ្ញាណជាតិផ្សេងៗគ្នា ទាំងអត្តសញ្ញាណធម្មជាតិ (ទឹកដី រុក្ខជាតិ មនុស្ស សត្វ ) ទាំងអត្តសញ្ញាណលទ្ធកម្ម (អត្តសញ្ញាណដែលមនុស្សបានបង្កើតឡើង) និងទាំងអត្តសញ្ញាណនិមិត្តរូប (និមិត្តសញ្ញានានាតំណាងជាតិ ទង់ជាតិ សញ្ញាជាតិ បាវចនាជាតិ...)។ អាវផាយសម្គាល់សម្លៀកបំពាក់របស់ស្ត្រីវៀតណាម។ ហូល ផាមួង សំពត់ ចងក្បិន អាវបំពង់វែងសម្គាល់សម្លៀកបំពាក់ស្ត្រីខ្មែរៗរូបស្នាំងជានិមិត្តសញ្ញាសម្គាល់ប្រទេសជាតិអាមេរិកជាដើម។ ទាំងនេះគឺជាអត្តសញ្ញាណសម្រាប់ប្រទេសជាតិនីមួយៗ។ចរិតរបស់ ជនជាតិនីមួយៗក៏ប្លែកគ្នាដែរ។ ចរិតរបស់បុគ្គលម្នាក់ៗវាជាបុគ្គលិកលក្ខណៈ ឬជាឥរិយាបថរបស់បុគ្គលក៏ពិតមែន តែចរិតរបស់អន្តរបុគ្គល (របស់ក្រុមណាមួយ) និងចរិតទូទៅរបស់ជនជាតិមួយពិតជាអត្តសញ្ញាណរបស់ជនជាតិនោះពុំអាចកែប្រែបានឡើយ។ **ដូចនេះ "ចរិតរបស់មនុស្សខ្មែរទូទៅគឺជាអត្តសញ្ញាណរបស់មនុស្សខ្មែរ"**។

តើអ្វីទៅជាចរិតរបស់មនុស្សខ្មែរ ដែលជាអត្តសញ្ញាណរបស់ជាតិខ្មែរនោះ?

I. **<u>និយមន័យ</u> ចរិត** តាមវចនានុក្រមខ្មែរបោះពុម្ពលើកទី៥ ទំ.១៨៩ សម្គាល់ឫកពា កិរិយាមារយាទបែបបទរបស់មនុស្ស។

ដូច<u>នេះ "ចរិតខ្មែរគឺឫកពា កិរិយាមារយាទ ឥរិយាបថរបស់មនុស្សខ្មែរទូទៅ ពុំមែនចរិតរបស់បុគ្គលខ្មែរណាម្នាក់ ឬរបស់មនុស្សខ្មែរមួយពួក (ចរិតរបស់អន្តរបុគ្គល) ណាមួយឡើយ"</u>។

II. <u>ចរិតខ្មែរតាមទស្សនៈនានា</u> : មានទស្សនៈមួយចំនួនបានលើកឡើងពីចរិតមនុស្ស ពិសេសមនុស្សខ្មែរនេះ។

១-<u>ពុទ្ធសាសនា</u> បានចែកមនុស្សជាប្រភេទទៅតាមចរិតរបស់បុគ្គលម្នាក់ៗគឺ ៖

1. រាគចរិត ចរិតស្រឡាញ់ស្អាតល្អ (ត្រេកត្រអាលក្នុងកាម)។
2. ទោសចរិត ចរិតប្រញាប់ប្រញាល់ ក្តៅក្រហាយប្រកបដោយកំហឹង។
3. មោហចរិត ចរិតដែលចូលចិត្តជឿ ហ៊ើសជឿ វង្វេងដោយខ្វះការពិចារណា។
4. វិតក្កចរិត ចរិតចូលចិត្តខ្វាយខ្វល់ តប់ប្រមល់ ចង្អៀតក្នុងចិត្ត។
5. ពុទ្ធិចរិត ចរិតចូលចិត្តត្រិះរិះច្រើន ឆ្លាត (ប្រើបញ្ញានិងចំណេះដឹង) (១)

នេះជាចរិតរបស់មនុស្សលោកទូទៅ រួមទាំងមនុស្សខ្មែរផងដែរ។

២-<u>លោក នុត ណារាំង</u> ក្នុងចរិតខ្មែររបស់លោក ប៊ុន ច័ន្ទម៉ុល លំនាំដើម

- ទំ.ជ "ខ្មែរចេះសម្របសម្រួល" (ចូលស្ទឹងតាមបត់) ចេះសម្របខ្លួនតាមសង្គមភាគច្រើន។
- ទំ.ឆ "ខ្មែរចូលចិត្តលាក់ចំណេះ" (ចេះ១០យ៉ាងច្រើនបង្រៀន៩) និង "ច្រើនសាកគ្រូ" (ពិសេសវិជ្ជាគុន) ខ្មែរឥស្សរៈសាកគ្រូ បាញ់សុគតសង្ឃមួយអង្គនៅកំពង់ស្ពឺ)។

៣-<u>លោក លី ស៊ីវ៉ែ</u> ក្នុងអរិយធម៌ខ្មែរទាក់ទងនឹងអក្សរសិល្ប៍ទំ.១៣១ បុរសខ្មែរច្រើនមានឫកខ្ជីខ្ជាប្រហែសច្រើន។

៤-<u>លោក សាគូ សាម៉ុត</u> ភូមិវិទ្យាប្រទេសកម្ពុជាទំ.៦៧ ខ្មែរមានចិត្តនឹងនរ ស្ងាត់ស្ងៀមប្រកបដោយជំនឿ និងច្រើនជាមនុស្សឧស្សាហ៍ធ្វើការងារ។

៥-<u>លោក ប៊ុន ចាន់ម៉ុល</u> តាមរយៈសៀវភៅ "ចរិតខ្មែរ" លោកវិភាគច្រើនលើចរិតខ្មែរនេះ រួមមាន ៖

- ខ្មែរមិនចេះគិតមុខក្រោយ (និយាយផ្លូចៗឲ្យតែរួចពីមាត់)
- ពុំចេះរក្សាការសម្ងាត់ (មាត់ត្រីកំភ្លាញ)
- ជឿពុំសមហេតុផល (មន្តអាគម កាប់មិនមុត ដុតមិនឆេះ...)
- ឃោរឃៅ (ខ្មែរឥស្សរៈ សម្លាប់រាស្ត្រពុំមានហេតុផលច្បាស់លាស់ គ្មានច្បាប់ គ្មានមនុស្សធម៌)
- ធ្វើការពុំចេះស្ទង់កម្លាំង (ពុំចេះប្រមាណសមត្ថភាពខ្លួន)
- ចង់ធ្វើធំតែឯង (ក្តោបអំណាច)
- ចង់ចាញ់ឈ្នះគ្នា ដោយពុំគិតប្រយោជន៍ជាតិ
- តួឯកនិយមផ្តាច់ការ (មេគេធ្វើអ្វីក៏ត្រូវទាំងអស់ មានតែអញដែលល្អ)
- ពូកែបន្ទោសគ្នា(គ្មានការទទួលខុសត្រូវ)។ពេលមានបញ្ហាកើតឡើងសតែងឆ្លើយដាក់គ្នា។
- បក្សពួកនិយម
- កាប់សម្លាប់គ្នាដើម្បីអញធំ
- ច្រើនលួចយកយោបល់គេ ធ្វើយោបល់ខ្លួនឯង

(១) កាសែតអន្តរាគមន៍លេខ១៨៥ ថ្ងៃច័ន្ទ ទី២០ កក្កដា ១៩៩៩ បរិយាយថ្ងៃនេះ "ត្រិះសុមត្ថភាពសម្បុរសធម៌៧" ដោយវិធុរបណ្ឌិត

- មិនព្រមពិគ្រោះយោបល់អ្នកដទៃ ខ្លាចអន់
- ខ្លាចនយោបាយ (ពុំសូវហ៊ានចូលរួមធ្វើនយោបាយ)
- សងសឹកសួពូជ (ស្អប់ គុំកួន និងសងសឹកប្រចាំត្រកូល)
- ផ្ចាញ់ផ្ចាលគ្នា គ្មានចិត្តកីឡា
- លោភ ពង្រេចពង្រិល (ដឹងថាអស់អំណាច រើយកតាំងពីកៅអី ឬបំផ្លាញចោល)
- ចង្រៃ បំផ្លាញជាតិ (សំលៀងកាំបិតលើខ្នងគោថ្ម)
- ស្វាពាក់មុដ (បញ្ចេញឫកឲ្យគេស្គាល់ជាតិកំណើតរបស់ខ្លួន)
- តឹងដំបូងក្រោយធូរយែត
- សង្ស័យគ្នាជានិច្ច
- បាក់ស្បាត

៦-<u>លោក វ៉ាន់ ឌីកាអុន</u> ប្រវត្តិសាស្ត្រប្រទេសកម្ពុជាមុនសម័យអាណានិគមបារាំងដល់បច្ចុប្បន្ន ភាគ១ទំ.៥៩ "ខ្មែរតែងគិតអ្វីៗទៅតាមមនោសញ្ចេតនា និយមការអាណិតអាសូរជាងគោលការណ៍ច្បាប់"ហេតុមានពាក្យទូន្មានថា "យល់ញាតិឃ្លាតច្បាប់"។

(នៅមានត) **លោក ស៊ឹមហាក់**

អតីតនាយកវិទ្យាល័យជាស៊ីម សាមគ្គី-ភ្នំពេញ

**<u>ចំណោទ ៨យ៉ាង</u>**

ចំណោទនេះអ្នកប្រាជ្ញតែងឡើងក្នុងរជ្ជកាលនៃ ព្រះបាទសម្តេចនរោត្តម ដែលនគរយើងធ្លាក់ទៅជាអាយ័តនៃបរទេស។

| | |
|---|---|
| ១- ចាក់ទឹកដូង | អំដូងមួយពាន់ |
| ២- កាច់ឈើឈ្នាន់ | អន្ទាន់អន្ទង |
| ៣- កាច់របង | រំលេងសីមា |
| ៤- កន្ទុយត្រីប្រា | មេនាងឧក |
| ៥- កន្ទុយត្រីផ្ទក់ | មេនាងកែវ |
| ៦- អកកំបោរ | ប្រចាំថង់ |
| ៧- បំពង់ឫស្សី | ប្រចាំវែក |
| ៨- ក្បាលទំពែក | ក្អែកជុះដាក់ប៉ក់ ។ |

-ស្រាយចំណោទទាំង ៨:

ទី១-ម៉ាស៊ីនទឹក, ទី២-តម្បាញ, ទី៣-ខ្សែលួស, ទី៤- ពស្ត្រយកគ្នាលែងរើសពូជ, ទី៥- ពស្ត្រយកប្រពន្ធជាតិស្តេច, ទី៦-ស្តេចឲ្យមានគ្រាន់តែចាំរាំង, ទី៧- នាម៉ឺនគ្រាន់តែជូសប្រយោជន៍ឲ្យគេ, ទី៨-អ្នកស្នេហាជាតិតែខ្នើក ជាប់គុក និរទេស សម្លាប់ចោល។ **យូរ អ៊ុន**

**កម្ពុជសុរិយា ឆ្នាំទី២៨ លេខ២ ខែកុម្ភៈ ៣/ស.២៤៩៨ គ.ស ១៩៥៦**

# ខដ្ឋារអប់រំកាយ

## តើគួរចាត់ទុកការអប់រំកាយជាវិជ្ជាមួយមានតម្លៃស្មើនឹងវិជ្ជាឯទៀតដែរឬទេ?

បើយើងក្រឡេកមើលទិដ្ឋភាពបច្ចុប្បន្ននៃទីប្រជុំជនខេត្ត/រាជធានីនោះយើងឃើញសកម្មភាពអប់រំកាយរីកស្គុសស្គាយទាំងព្រឹកទាំងល្ងាច។ យើងពុំចាំបាច់រៀបរាប់អំពីប្រយោជន៍ និងគោលបំណងនៃការអប់រំកាយផងទេ។ យើងគ្រាន់តែលើកយក "ពាក្យអប់រំកាយ" មកពន្យល់ក៏យើងអាចឆ្លើយនឹងសំណួរខាងលើនេះបានដោយងាយ។អប់រំសិស្សបានសេចក្ដីថាយើងបង្កើនសមត្ថភាពខាងផ្លូវបញ្ញា សីលធម៌ ផ្លូវកាយ និងផ្លូវសិល្បារម្មណ៍ ( esthétique )។

តាមន័យនេះយើងបានឃើញយ៉ាងច្បាស់ថាការអប់រំមានគោលបំណងបង្កើនសមត្ថភាពទាំងផ្លូវចិត្តទាំងផ្លូវកាយ។ ពិតជាងនេះទៅទៀតការអប់រំផ្លូវចិត្តគ្រាន់តែជាផ្នែកមួយនៃការអប់រំទូទៅតែប៉ុណ្ណោះ។ ចំណែកការអប់រំផ្លូវកាយវិញអាចបង្កើនសមត្ថភាពផ្លូវកាយផងហើយនិងសមត្ថភាពផ្លូវចិត្តថែមទៀតផង។

អាស្រ័យហេតុនេះ គ្រូយើងមិនត្រូវធ្វេសប្រហែសការអប់រំកាយជាដាច់ខាត។

## តើវប្បធម៌ខ្មែរយើងបានយកចិត្តទុកដាក់ក្នុងវិជ្ជាអប់រំកាយនេះដែរឬទេ?

ខ្មែរយើងជាជនជាតិមួយមានអារ្យធម៌ដូចជាតិនានាដែរ។ហេតុនេះខ្មែរយើងក៏យកចិត្តទុកដាក់ចំពោះការអប់រំកាយដែលជាផ្នែកមួយសំខាន់នៃអារ្យធម៌ដែរ។ការអះអាងនេះមានភស្តុតាងស្រាប់ក្នុងទស្សនៈពុទ្ធនិយមដែលជាមូលដ្ឋានធំរបស់មហាជនខ្មែរយើង។ព្រះពុទ្ធជាម្ចាស់លោកបានឲ្យតម្លៃជាវិសេសទៅលើកម្លាំងកាយ ដូចជាត្រង់ព្រះអង្គអនុវត្តនូវទុក្ករកិរិយាអស់៦ព្រះវស្សា ធ្វើបាបកាយឲ្យស្គាំងស្គមស្ទើរតែគ្មានកម្លាំងកំហែងអ្វីទាល់តែសោះ។ធ្វើយ៉ាងនេះដើម្បីផ្ដាច់ចិត្តឲ្យឃ្លាតពីកាយ។ប៉ុន្តែការផ្ដាច់ចិត្តឲ្យចេញពីកាយនេះពុំអាចនាំឲ្យព្រះអង្គរកសម្មាសម្ពោធិញ្ញាណឃើញទេ លុះត្រាតែព្រះអង្គត្រឡប់មកឆាន់ដូចដើមវិញ ដើម្បីឲ្យមានសុខភាពបរិបូណ៌ទើបព្រះអង្គបានសម្រេចសម្មាសម្ពោធិញ្ញាណ។

មិនតែប៉ុណ្ណោះ ការនិយមឱ្យតម្លៃទៅលើសមត្ថភាពកាយមានបញ្ជាក់ជាច្រើនទៀត តាមបុរាណប្រាសាទក្នុងអត្ថបទអក្សរសិល្ប៍ (littérature) ក៏ដូចជាក្នុងល្បែងទំនៀមទម្លាប់របស់មហាជនខ្មែរយើងដែរ រូបចម្លាក់ទាញព្រ័ត្រនៅមុខខ្លោងទ្វារចូលទៅនគរធំ រឿងចៅធុង ចៅសាញ់ ល្បែងទាត់សី ប្រដាល់ គុនដំបង បាញ់ធ្នូ អ៊ុ បេះត្រឡាច ហ៊ីង ខ្លែងឆាបកូនមាន់ កូនគោលក្នុងទឹក លើគោក បោះឈូង បោះអង្គញ់។ល។ ទាំងអស់នេះសុទ្ធតែឲ្យតម្លៃទៅលើសមត្ថភាពកាយទាំងអស់

នេះសឲ្យឃើញថាអារ្យធម៌ខ្មែរយើងបានគិតគូរការអប់រំកាយ ដើម្បីបង្កើនសមត្ថភាពផ្លូវកាយឲ្យស្មើនឹងការអប់រំដើម្បីបង្កើនសមត្ថភាពផ្លូវចិត្តដែរ។

ក្នុងការសិក្សាស្រាវជ្រាវវិជ្ជាអ្វីមួយ គេតែងតែខិតខំរិះរកឲ្យឃើញនូវធាតុ (élément) នូវវិធី (méthode) និងនូវធម្មភាព (lois) នៃវិជ្ជានោះជាចាំបាច់។ ដូច្នេះការលើកយក ការអប់រំកាយមកសិក្សាក៏ត្រូវស្ថិតនៅលើមូលភាព (principe) ខាងលើនេះដែរ។

**ធាតុនៃការអប់រំកាយ**

១.ប្រភេទនៃការហាត់

ក.ការហាត់ទ្រទ្រង់សរីរាង្គកាយ (exercices de maintien)

ខ.បរិវច្ឆណកម្ម (exercices préparatoires)

គ.ការហាត់តាមធម្មជាតិវិធី (exercices par méthode naturelle)

ឃ.ការអប់រំវិជ្ជាកីឡា (éducation sportive)

ង.ការអប់រំចង្វាក់ (éducation rythmique)

ច.ល្បែង (jeux)

ឆ.កីឡា (sports)

២.វាទនៃការអប់រំកាយ (théorie de l' éducation physique)

៣.មូលភាពនៃការអប់រំកាយ (Principes de l' éducation physique)

៤.មូលធម៌នៃការអប់រំកាយ (fondement de l' éducation physique)

៥.ប្រវត្តិនៃការអប់រំកាយ (histoire de l' éducation physique)

**វិធីនៃការអប់រំកាយ**

ការបញ្ជាក់ថា តើការអប់រំកាយត្រូវប្រើវិធីណានោះ ជាការលំបាកបំផុតព្រោះថាទោះបីអ្នកឯកទេសជំនាញយ៉ាងណាក៏ដោយ ក៏ពុំទាន់ហ៊ានធានាអះអាង វិធីនេះត្រូវ វិធីនោះខុស ដោយមកពីវិជ្ជាអប់រំកាយជាវិជ្ជាដែលកំពុងតែកកើតនៅឡើយ។

អាស្រ័យហេតុនេះ យើងសូមបញ្ជាក់ថា ក្នុងការអប់រំកាយគ្រូយើងអាចប្រើវិធីណាក៏ដោយឲ្យតែវិធីនោះអនុវត្តទៅតាមហើយបានលទ្ធផលល្អដូចរៀបរាប់ខាងក្រោមនេះ។

**ការអប់រំកាយធ្វើឲ្យ**

១.មានសុខភាពមកពីៈ

ក.ធ្វើឲ្យក្មេងលូតលាស់ស្រួលខាងរូបរាងកាយ

ខ.ធ្វើឲ្យសរីរាង្គក្នុងខ្លួនដើរបានស្រួល ការដកដង្ហើម ដំណើរឈាមរត់ ការរំលាយអាហារ។ល។

២.មានរាងរៅសមសួន

៣.បានចំណេញក្នុងការងារ ធ្វើឱ្យមនុស្សអាចបង្កើនសមត្ថភាពកាយបានជាអតិបរមា ធ្វើឲ្យអ្នកមានការប៉ិនប្រសប់ ក្នុងមុខរបរ ដូចជាកីឡា របាំ ភ្លេង។ល។

៤.សង្គមរីកចម្រើន

៥.មានការលូតលាស់ខ្លាំងខាងផ្លូវបញ្ញា

៦.មានការលូតលាស់ខាងផ្លូវសីលធម៌

ដើម្បីជ្រើសរើសវិធីឲ្យបានត្រឹមត្រូវ យើងត្រូវគោរពមូលភាពសំខាន់ៗដូចតទៅនេះ៖

១.យើងមិនត្រូវធ្វេសប្រហែសសមត្ថកិច្ចណា ដែលមានការអប់រំកាយអាចបង្កើនសមត្ថភាពកាយសិស្សឡើយ។

២.ការអប់រំកាយត្រូវផ្អែកទៅលើវិទ្យាសាស្ត្រផង (ជីវវិទ្យា និងចិត្តវិទ្យា) ទៅលើគរុកោសល្យផង។

៣.ត្រូវយកចិត្តទុកដាក់នឹងពុទ្ធិថ្មីណា (connaissance) ដែលវិទ្យាសាស្ត្រទើបរកឃើញ ហើយដែលគួរកែប្រែ វិធីអប់រំកាយចាស់ចេញ។

៤.វិធីណាដែលបានពិសោធន៍តាមបែបគរុកោសល្យរួចហើយ តែត្រូវយកមកប្រើប្រាស់ក្នុងការបង្រៀន។

៥.សម្រាប់យើងវិធីណាមួយថា ជាការត្រឹមត្រូវបាន លុះត្រាតែយើងយកវិធីនោះទៅពិសោធជាច្រើនដង លើក្មេងប្លែកៗគ្នារួចហើយ។

## ធម្មភាពនៃការអប់រំកាយ

ដើម្បីដឹកនាំការអប់រំកាយឲ្យបានលទ្ធផលល្អ យើងត្រូវអនុវត្តនូវធម្មភាពដូចខាងក្រោម៖

១.វឌ្ឍនភាព (progression)

២.បដិបក្ខ (contradiction ou alternance)

៣.បរិមាណ (dosage)

៤.និរន្តរភាព (continuité)

ការរៀបរាប់មកខាងលើនេះ គ្រាន់តែចង់បង្ហាញពីសារៈសំខាន់នៃវិជ្ជាអប់រំកាយ ដែលបច្ចុប្បន្នវិជ្ជានេះត្រូវបានពិភពលោករាប់អាននិងយកចិត្តទុកដាក់ណាស់៕

**លោក ចែម ផាន**

អធិការបឋមសិក្សា.បរិញ្ញាបត្រគ្រប់គ្រង.បរិញ្ញាបត្រប្រវត្តិវិទ្យា




## យោបល់នឹងការពន្យល់ខ្លះៗ អំពីតារាងប្រវត្តិកាល នៃអក្សរសាស្ត្រខ្មែរ (ត)

### តារាងប្រវត្តិកាលនៃអក្សរសាស្ត្រខ្មែរខ្លះតាំងពីសតវត្សរ៍ទី១៥ ដល់ទី១៩ (អំឡុង ៥០០ឆ្នាំ)

| ល.រ | ឈ្មោះរឿងផ្សេងៗ | របៀបនិពន្ធ | នាមអ្នកនិពន្ធ | ស.វត្សរ៍ ឬ គ.ស | រជ្ជកាលផ្សេងៗ |
|---|---|---|---|---|---|
| ១ | សិលាចារឹកនគរវត្ត | ពាក្យចារឹកខាងចុងជាពាក្យកាព្យ | លោកសីដេសចូលរួបរួមងពាក្យកាព្យខាងចុងរបស់បណ្ឌិតជ័យនន្ទ | សតវត្សរ៍ទី១៥ ដល់១៨ | រវាងរាជ្យព្រះបាទធម្មោរាជាទី១ ទល់នឹងរាជ្យ ព្រះបាទអង្គអេង។ |
| ២ | (១)<br>រាមកេរ្តិ៍ខ្សែទី១ ដល់១០<br>ខ្សែ៧៥ដល់ ៨០ | ពាក្យកាព្យ<br>(បទល្ខោន) | ?<br>? | អំឡុងសតវត្សរ៍ ទី១៧-១៨?<br>ទី ១៨-១៩? | រវាងរាជ្យព្រះបាទជ័យជេដ្ឋាទី៨មកទល់នឹងរាជ្យព្រះបាទអង្គអេង<br>រវាងរាជ្យព្រះបាទអង្គអេង មកទល់នឹងរាជ្យព្រះបាទអង្គឌួង |
| ៣ | ដាវរឿង | ពាក្យកាព្យ | ឧកញ៉ាចក្រី (កែវ) | ១៥៣៤ | ព្រះបាទអង្គច័ន្ទទី១ |
| ៤ | ល្បើកអង្គរ | ពាក្យកាព្យ | អ្នកប៉ាង | ១៥៩៨ | ព្រះបាទព្រះរាជសម្ភារ |

(១)- សូមឲ្យមើលន័យលក្ខណៈខាងចុងតារាងប្រវត្តិកាលនេះ

| | | | | | |
|---|---|---|---|---|---|
| ៥ | កំណាព្យថ្លែងក្ដីស្នេហា(សរសើរហេមន្តមាសជាដើម) | ពាក្យកាព្យ | ព្រះបាទព្រះរាជសម្ភារ | ១៦២៩-១៦៣៤ | ព្រះបាទព្រះរាជសម្ភារ |
| | ច្បាប់ព្រះរាជសម្ភារ | ពាក្យកាព្យ | ព្រះបាទព្រះរាជសម្ភារ | ១៦២៩-១៦៣៤ | ព្រះបាទព្រះរាជសម្ភារ |
| ៦ | ខ្យងស័ង្ខ | ពាក្យកាព្យ | ក្រុមព្រះនិពន្ធព្រះបាទជ័យជេដ្ឋា | ១៦៩៣ | ព្រះបាទជ័យជេដ្ឋាទី៤ |
| ៧ | ព្រះរាជក្រឹត្យក្រមផ្សេងៗ | ពាក្យរាយ | ក្រុមព្រះនិពន្ធព្រះបាទជ័យចេស្ដា | ១៦៩៣-១៦៩៧ | ព្រះបាទជ័យចេស្ដា (ពញាសូ) |
| ៨ | ច្បាប់ចាស់ | ពាក្យកាព្យ | ព្រះបាទសត្ថាទី២ | ១៧២២-១៧២៩ | ព្រះបាទសត្ថាទី២ |
| ៩ | ច្បាប់សុភាសិត | ពាក្យកាព្យ | ឧកញ៉ាវង្សាសារពេជ្ជ(នង) | ១៧៩០ | ព្រះបាទអង្គអេង |
| ១០ | លោកន័យជាតក | ពាក្យកាព្យ | - វង្សាក្សត្រី (នង) | ១៧៩៤ | ព្រះបាទអង្គអេង |
| ១១ | បុញ្ញសាសិរសា | ពាក្យកាព្យ | - វង្សាក្សត្រី (នង) | ១៧៩៧ | ព្រះបាទអង្គអេង |
| ១២ | ក្រុងសុភមិត្រ | ពាក្យកាព្យ | - កោសាធិបតី (កៅ) | ១៧៩៨ | ព្រះបាទអង្គច័ន្ទទី២ |
| ១៣ | ភោគកុលកុមារ | ពាក្យកាព្យ | ឧកញ៉ាព្រះឃ្លាំង (នង) | ១៨០៤ | ព្រះបាទអង្គច័ន្ទ ទី២ |
| ១៤ | វរនុជវរនេត្រ | ពាក្យកាព្យ | ចៅហ្វាយឃ្លាំង (មៀច) | ១៨០៦ | -ដ- |
| ១៥ | ចំប៉ាថោង | ពាក្យកាព្យ | ព្រះបាទអង្គដួង | ១៨១០ | -ដ- |
| ១៦ | របាក្សត្រ | ពាក្យកាព្យ | ព្រះបទុមបារមី (ពេជ្យ) | ១៨១៥ | -ដ- |
| ១៧ | ល្បើកជេតពន | ពាក្យកាព្យ | ឧកញ៉ាសោទស (ខែក) | ១៨១៥ | -ដ- |
| ១៨ | រឿងកាកី | ពាក្យកាព្យ | ព្រះបាទអង្គដួង | ១៨១៥ | -ដ- |
| ១៩ | ក្រមចៅហ្វាយស្រុក | ពាក្យរាយ | ? | ១៨២៩ | ព្រះបាទអង្គច័ន្ទទី២ |
| ២០ | រឿងមុចលិន្ទ (ចន្ទគោរព) | ពាក្យកាព្យ | បណ្ឌិតស្អាត | ១៨៣៣ | ព្រះរាជក្សត្រីព្រះអង្គម៉ី |
| ២១ | ព្រះរាជក្រឹត្យក្រម | ពាក្យរាយ | ? | អំឡុង | ព្រះបាទ |

| | | | | | |
|---|---|---|---|---|---|
| | ផ្សេងៗ | | | ស.វទី១៨-១៩ | អង្គឌួង |
| ២២ | **ទសជាតក**<br>តេមិយជាតក<br>មហាជនកជាតក<br>សុវណ្ណសាមជាតក<br>នេមិរាជជាតក<br>មហោសថជាតក<br>ភូរិទត្តជាតក<br>ចន្ទកុមារជាតក<br>ព្រហ្មនារទជាតក<br>វិធុរបណ្ឌិតជាតក<br>វេស្សន្តរជាតក | ពាក្យទេសនា | ? | អំឡុង<br>ស.វទី១៨-១៩ | ព្រះបាទអង្គឌួង |
| ២៣ | បឋមសម្ពោធិ៍ | ពាក្យទេសនា | ? | ទី១៨-១៩ | ព្រះបាទអង្គឌួង |
| ២៤ | ត្រៃភូមិ | ពាក្យទេសនា | ព្រះបាទរាជាលេទៃ | ទី១៨-១៩ | ព្រះបាទអង្គឌួង |
| ២៥ | រឿងជិនវង្ស | ពាក្យកាព្យ | អរិយគាមិនី (ភឹង) | ១៨៥៦ | ព្រះបាទអង្គឌួង |
| ២៦ | រឿងពេជតា | ពាក្យកាព្យ | ធម្មបញ្ញា (ម៉ែន) | ១៨៥៧ | ព្រះបាទអង្គឌួង |

(នៅមានត)

**លោក ញ៉ុក ថែម**
មជ្ឈដ្ឋានផ្នែកស្រាវជ្រាវនៅវិទ្យាស្ថានជាតិគរុកោសល្យ ក្រុងភ្នំពេញ

"ស្រឡាញ់ស្រីខ្មៅ ស្រីខ្មែរមានផៅ មានភ័ក្ត្រកាល
ត្រកូលមានយស ខ្ពង់ខ្ពស់វិសាល វិសេសពៅពាល
ពៅពេញជំទង់ ។

ជំទើរមានរាង មានរូបស្អាតស្អាង ស្អាតស្អំសមទ្រង់
សមទ្រូងទូលាយ ឆោមឆាយត្រចង់ ត្រចះផូរផង់
ផូរភ័ក្ត្រផ្កាថ្លៃ ។"

ឧកញ៉ាសន្ធរវោហារម៉ុក

ទស្សនាវដ្ដីមិត្តសាលាបាលី ឆ្នាំទី២ លេខ១ (១៩៥១)

## តើហេតុដូចម្តេចបានជាខែកុម្ភៈមានតែ២៨ ឬ២៩ថ្ងៃ?

នេះជារឿងមិនចង់ចាញ់របស់ប្រមុខដឹកនាំអាណាចក្ររ៉ូម (ប្រទេសអ៊ីតាលីបច្ចុប្បន្ន) ដែលមានឈ្មោះថា Augustus កាលពីជាង ២០០០ឆ្នាំមុន។ រឿងនេះទាក់ទងនឹងការបង្កើតប្រតិទិន-សុរិយគតិជាលើកដំបូងដោយ Julius Caesar ជាប្រមុខដឹកនាំអាណាចក្ររ៉ូមមុន Augustus ។

យើងត្រូវដឹងថាសម័យកាលនោះរ៉ូមជាមហាអំណាចលើពិភពលោកមានដែនអាណាចក្រគ្របដណ្តប់លើពេញទូទាំងទ្វីបអឺរ៉ុប និងភូមិភាគអាហ្វ្រិកខាងជើង មានប្រទេសអេស៊ីបជាដើម។

ដោយយល់ឃើញថាប្រតិទិនចន្ទគតិមិនមានភាពទៀងទាត់ធ្វើឲ្យមានផលអាក្រក់ដល់-កសិកម្ម Julius Caesar បានបង្គាប់បញ្ជាឲ្យប្រើដំណើរព្រះអាទិត្យពោលគឺ Equinox និងSolstice ជាគោលក្នុងការបង្កើតប្រតិទិនសុរិយគតិ។

ដំបូងឡើយគេបានសាកល្បងរូបមន្ត (៣១x៦) + (៣០x៦) = ៣៦៦ថ្ងៃ ហើយខែកុម្ភៈជាខែទី១២ ក្រោយគេ ឃើញថាមិនទាន់ត្រូវល្អគឺវាងលើសចម្មតា គេដក ១ថ្ងៃពី ខែកុម្ភៈដែលជា-ខែចុងក្រោយសល់ត្រឹម២៩ថ្ងៃ។ ក្រោយមកខែកុម្ភៈត្រូវបានយកមកដាក់ជាខែទី២វិញ។ មួយឆ្នាំពិតប្រាកដមាន៣៦៥ថ្ងៃ នឹង៦ម៉ោង ដូច្នេះបួនឆ្នាំម្តងត្រូវដំឡើង ១ថ្ងៃលើខែកុម្ភៈ គឺ៣០ថ្ងៃ។

Julius Caesar បានយកឈ្មោះគាត់ Julius ដាក់ជាឈ្មោះខែទី៧ Julius នេះជាឈ្មោះភាសា Latin ជាអង់គ្លេស July និងជាបារាំង Juillet។ដោយសារ Augustus ជាក្មួយរបស់គាត់ជាកូនចិញ្ចឹមរបស់គាត់ផង ថែមទាំងជាអគ្គសេនាដៃស្តាំគាត់ទៀត គាត់បានយកឈ្មោះ Augustus ដាក់ជាខែទី ៨ បានជាអង់គ្លេស August និងបារាំង AoÛt។ Julius Caesar ត្រូវបានគេធ្វើឃាតនៅឆ្នាំ៤៤ មុនគ្រិស្តសករាជ។បន្ទាប់ពីបានកម្ចាត់ពួកឃាតករបស់ឪពុកចិញ្ចឹមរបស់ខ្លួនអស់ហើយAugustus បានឡើងធ្វើជាប្រមុខអាណាចក្ររ៉ូមពេលនោះគាត់បានបញ្ជាកំណត់ឲ្យខែរបស់គាត់មាន៣១ថ្ងៃ ដូចខែរបស់Juliusដែរ។គេក៏ដកមួយថ្ងៃ អំពីខែកុម្ភៈមកថែមឲ្យខែសីហាតាមការកំណត់របស់ Augustus ។ ដូច្នេះហើយទើបខែកុម្ភៈមានត្រឹម ២៨ថ្ងៃហើយ ៤ឆ្នាំមាន ២៩ថ្ងៃម្តង។

មួយឆ្នាំប្រាកដមែនទែនមាន ៣៦៥ថ្ងៃ ៥ម៉ោង ៤៨នាទី និង ៤៥វិនាទី៕

**គេហទំព័រ (៥០០០ឆ្នាំ)**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សមាគមបុគ្គលិកសិក្សាខ្មែរ
គណៈកម្មាធិការកណ្តាល
លេខ: ១៦/១៨ គ.ក

## សេចក្តីជូនដំណឹងមរណភាពប្រចាំខែ ឧសភា ឆ្នាំ២០១៨
## តាងនាមសមាគមបុគ្គលិកសិក្សាខ្មែរទាំងមូលគណៈកម្មាធិការកណ្តាលនៃ ស.ប.ស.ខ.
## សូមសម្តែងក្តីសោកស្តាយជាទីបំផុតចំពោះការបាត់បង់ជីវិតនៃមិត្តយើង និងគ្រួសារ
## ហើយសូមចូលរួមរំលែកទុក្ខមរណសញ្ញាជាមួយគ្រួសារនៃសពទាំងនោះ

| ល.រ | គោត្តនាម-នាម | អាយុ | ភេទ | ក្របខ័ណ្ឌ | អង្គភាពបម្រើការងារ | ថ្ងៃខែឆ្នាំមរណៈ | មូលហេតុ | លេខប័ណ្ណ | សពទី |
|---|---|---|---|---|---|---|---|---|---|
| | | | | | ក.មរណភាពសមាជិក | | | | |
| 1 | ឆែម ប៊ុន | ៧៦ | ប | បឋម | និ.ជនបឋមបាយដំរាំស្រុកបាណន់ ខេត្តបាត់ដំបង | 29.12.17 | រោគាពាធ | 3460បប | 12723 |
| 2 | ឃិន ទីប៊ូ | ៨៦ | ប | មទក | វិទ្យាល័យ ថ្មគោល ស្រុក ថ្មគោល ខេត្តបាត់ដំបង | 07.01.18 | គេគាណុស | 5567បប | 12724 |
| 3 | មៀន ណាខុម | ៨១ | ស | មបក | និវត្តជនភារិៈអប់រំក្រុងបាត់ដំបង | 01.02.18 | រោគាពាធ | 295បប | 12725 |
| 4 | អ៊ុច នឿន | ៨៦ | ប | មបក | អនុវិទ្យាល័យ តាហែន ស្រុក សង្កែ ខេត្តបាត់ដំបង | 04.02.18 | ចរាចរ | 5629បប | 12726 |
| 5 | អ៊ី សុខុម | ៥៣ | ប | បឋម | និវត្តជន បឋម ភូមិស្ពាន ថ្មគោល ខេត្តបាត់ដំបង | 08.02.18 | ជរាពាធ | 1758បប | 12727 |
| 6 | ឡាច វ៉ាង | ៧៥ | ប | បឋម | និវត្តជន បឋម ស្នឹង ស្រុកបាណន់ ខេត្តបាត់ដំបង | 23.02.18 | រោគាពាធ | 3266បប | 12728 |
| 7 | នួន ចុន | ៧៣ | ប | បឋម | និវត្តជនការ.អយក.ព្រះស្តេច ខេត្តព្រៃវែង | 26.01.18 | រោគាពាធ | 314ពវ | 12729 |
| 8 | វ៉ា ឆុន | ៧៣ | ប | មូលដ្ឋាន | និវត្ត.អនុវិ.ធាយ. ស្រុក បាភ្នំ ខេតព្រៃវែង | 16.02.18 | ជំងឺ | 8012ពវ | 12730 |
| 9 | អោក ណេ | ៤៥ | ប | បឋម | មន្ទីរដែនដីនគរូបនីយកម្ម និងសំណង់ ខេត្តព្រៃវែង | 13.02.18 | រោគាពាធ | 2362ពវ | 12731 |
| 10 | ឡាយ សុចិន្តា | ៣៣ | ប | មូលដ្ឋាន | អនុ.បន្ទិចប្រាសាទ ស្រុកពាមរក៍ ខេត្តព្រៃវែង | 14.02.18 | គាំងបេះដូង | 9431ពវ | 12732 |
| 11 | ជុំ ជីម | ៦៩ | ប | បឋម | និ.ជន បឋម.ទឹកថ្លា  ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង | 28.02.18 | រោគាពាធ | 3919ពវ | 12733 |
| 12 | អ៊ុច គីមសាន | ៧៦ | ប | មូលដ្ឋាន | និវត្ត.មន្ទីអប់រំ ខេត្តព្រៃវែង | 26.02.18 | រោគាពាធ | 100ពវ | 12734 |
| 13 | អេង ម៉េងឈាង | ៦៤ | ប | បឋម | និវត្ត.ប.ពេជ្រមុនីរត្ន ស្រុកពារាំង ខេត្តព្រៃវែង | 17.02.18 | ជំងឺ | 6159ពវ | 12735 |
| 14 | នង ចាន់លី | ៦៣ | ស | បឋម | និវត្ត.ប.បាប្រិយ៍ ស្រុក ស៊ីធរកណ្តាល ខេត្តព្រៃវែង | 18.03.18 | រោគាពាធ | 3165ពវ | 12736 |
| 15 | ញៀប សាលន់ | ៦៦ | ស | បឋម | និវត្ត.ប.ហស អ្នកលឿង ស្រុកពាមរក៍ ខេត្តព្រៃវែង | 02.03.18 | រោគាពាធ | 5335ពវ | 12737 |
| 16 | ម៉ុច ម៉េងស៊ា | ៧៦ | ប | មូលដ្ឋាន | និវត្ត.អនុ.បឹងព្រះ ស្រុកបាភ្នំ ខេត្តព្រៃវែង | 24.02.18 | រោគាពាធ | 4450ពវ | 12738 |
| 17 | មាស សែ | ៦៦ | ប | បឋម | និវត្ត.ប.ស្វាយអាត់ ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង | 19.03.18 | រោគាពាធ | 3752ពវ | 12739 |
| 18 | សៅ វ៉ា | ៤៦ | ស | បឋម | ប.ស្នឹងស្លត ស្រុកពាមរក៍ ខេត្តព្រៃវែង | 21.02.18 | រោគាពាធ | 3369ពវ | 12740 |
| 19 | នាង ណារី | ៥១ | ប | បឋម | ប.គោកគង់លិច ស្រុក កញ្ជៀច ខេត្តព្រៃវែង | 01.03.18 | មហារីកថ្លើម | 1630ពវ | 12741 |
| 20 | ហេង ស្រីមុំ | ៣៤ | ប | បឋម | ប.ស្វាយពល ស្រុកពារាំង ខេត្តព្រៃវែង | 17.03.18 | មហារីកដោះ | 8679ពវ | 12742 |
| 21 | ហួត វុទ្ធី | ៤២ | ប | បឋម | ប.ស្វាយសុខោ ក្រុងព្រៃវែង ខេត្តព្រៃវែង | 08.03.18 | ជំងឺ | 2379ពវ | 12743 |
| 22 | កុយ ចាន់ណារី | ៦១ | ស | បឋម | និវត្តជន ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង | 04.03.18 | លើសឈាម | 1576ស្វរ | 12744 |
| 23 | ស្មោញ ណយ | ៨២ | ប | បឋម | និវត្តជន ស្រុករមាសហែក ខេត្តស្វាយរៀង | 27.02.18 | របេងសួត | 971ស្វរ | 12745 |
| 24 | ធៀម រី | ៦៦ | ប | បឋម | និ.ជន បឋម. មហាសាមគ្គី ក្រុងកំពត ខេត្ត កំពត | 12.02.18 | រោគាពាធ | 2833កព | 12746 |
| 25 | ម៉ៅ ហួរ | ៦៥ | ប | បឋម | និ.ជន បឋម. កំពង់គ្រែង ស្រុកទឹកឈូ ខេត្តកំពត | 06.03.18 | រោគាពាធ | 307កព | 12747 |
| 26 | ដោក គៀម | ៦៧ | ស | បឋម | និ.ជន បឋម. ក្បាលដំរី ស្រុក គីរីវង់ ខេត្តតាកែវ | 16.09.17 | រោគាពាធ | 5323តក | 12748 |
| 27 | ជិន ងួន | ៤៧ | ប | បឋម | បឋមសិក្សា ឃ្លាំង សៀម ស្រុកបាទី ខេត្តតាកែវ | 18.09.17 | រោគាពាធ | 1502តក | 12749 |
| 28 | ម៉ម សុភាព | ៤៧ | ស | បឋម | បឋម. ហ.ស. ឈូកស ស្រុក សំរោង ខេត្តតាកែវ | 01.10.17 | មហារីកថ្លើម | 3478តក | 12750 |
| 29 | ចាន់ សុជាត | ៦០ | ប | ម.កំ១ | និវត្តជន វិទ្យា. ថ្នល់បំបែក ស្រុកទ្រាំង ខេត្តតាកែវ | 03.11.17 | ទឹកនោមផ្អែម | 0486គ.ក | 12751 |
| 30 | ជួប សារ៉េត | ៥០ | ប | បឋម | បឋមសិក្សា ព្រៃម្លូ ស្រុកកោះអណ្តែត ខេត្តតាកែវ | 16.09.17 | ចរាចរ | 3918តក | 12752 |
| 31 | គីម ប៊ី | ៦៣ | ស | ម.កំ១ | និ.ជន អនុ.ក្រពុំឈូក ស្រុកកោះអណ្តែត ខេត្តតាកែវ | 12.01.18 | គ្រោះថ្នាក់ ចរាចរ | 2075តក | 12753 |
| 32 | នូ ស៊ីនឿន | ៣៥ | ប | បឋម | បឋម. ក្រពុំឈូក ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ | 17.09.17 | ដាច់សសៃឈាម | 394ឧជ | 12754 |
| 33 | រាជ សុខន | ៦២ | ស | ម.កំ១ | និវត្តជន .ម.អ.យ.ក. ខេត្ត ឧត្តរមានជ័យ | 01.12.17 | គ្រោះថ្នាក់ ចរាចរ | 028ឧជ | 12755 |
| 34 | អ៊ុក សារឿន | ៦៧ | ប | ម.កំ១ | និ.ជន វិទ្យា. .ហ.ស.មង្គលបពិត្រ បរសេដ្ឋ កំពង់ស្ពឺ | 09.03.18 | គ្រោះថ្នាក់ ចរាចរ | 2714កស្ព | 12756 |
| 35 | លឹម លីគីម | ៤៩ | ប | ម.កំ១ | វិទ្យា .ហ.ស កំពង់ភ្នំ ស្រុកលើកដែក ខេត្តកណ្តាល | 18.02.18 | លើសឈាម | 1913កណ | 12757 |
| 36 | លន់ ផល | ៤៩ | ប | កំ.ឧត្តម. | វិទ្យាល័យ.ហ.ស.តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល | 25.02.18 | លើសឈាម | 4049កណ | 12758 |
| 37 | ប៊ុយ ប៊ុណ្ណារ៉េត | ៦៥ | ប | បឋម | និវត្តជន.បឋម.យសមេត្រី.អង្គស្នួល. ខេត្ត កណ្តាល | 24.02.18 | មហារីកប្លោកនោម | 4876កណ | 12759 |
| 38 | ឡឹក សាវ៉ាន | ៦៤ | ប | កំ.ឧត្តម. | និវត្តជន. វិ.ហស សិរីជីជុះ គៀនស្វាយ ខេត្តកណ្តាល | 26.02.18 | ក្រិនថ្លើម | 3850កណ | 12760 |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 26 | ហេង ហ៊ិន | ៧៦ | ស | កសិករ | ប្រពន្ធលោក ទង ឈីន និវត្តជន អនុវិទ្យា. បន្ទាយដែក ខេត្តកណ្តាល | 08.02.2018 | ក្រិនថ្លើម | 726កណ | 7224 |
| 27 | យ៉ុង មករា | ២៩ | ប | កសិករ | ប្តីអ្នកគ្រូ ជ៉ត ស្រីនាង បឋមក្រោះប្រាក់ ស្រុកគៀនស្វាយ ខេត្តកណ្តាល | 22.01.18 | ជំងឺគ្រាប់ឈាម | 12594កណ | 7225 |
| 28 | លឹម លីគីម | ៤៩ | ប | ម.កំ2 | ប្តីអ្នកគ្រូ សាលុក សារ៉ា វិទ្យាល័យ ហ ស កំពង់ភ្នំ ស្រុកលើកដែក ខេត្តកណ្តាល | 18.02.18 | លើសឈាម | 1954កណ | 7226 |
| 29 | ហុង សុខនី | ៦៩ | ស | មេផ្ទះ | ប្រពន្ធលោកជុំ ឈឿន វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ការគ្រប់គ្រង ឥ/ក | 31.03.18 | ជរាពាធ | 128គក | 7227 |
| 30 | ឆាត់ គាន | ៥៦ | ស | មេផ្ទះ | ប្រពន្ធលោកថុក សំអុន បឋម.យាន វៀនស្រុកស្វាយចេក ប.មានជ័យ | 31.03.18 | លើសឈាម | 2650បជ | 7228 |
| 31 | ម៉ា ណេង | ៤៣ | ស | កសិករ | ប្រពន្ធលោកគ្រូ ប៉ាក ប៊ុន្នី អនុវិទ្យាល័យ ឆាងវ៉ែង ស្រុកដងទង់ ខេត្តកំពត | 29.03.18 | ជរាពាធ | 2585កព | 7229 |
| 32 | ស៊ិន សុភាព | ៣៥ | ស | មេផ្ទះ | ប្រពន្ធលោកគ្រូ សេងសារុន បឋមសិក្សា ដងទង ស្រុកដងទង់ ខេត្តកំពត | 24.03.18 | គ្រោះថ្នាក់ចរាចរ | 4884កព | 7230 |
| 33 | ឌុច សាវុធ | ៥៤ | ប | ប្រជាជន | ស្វាមី អ្នកគ្រូ កែវ ណារី បឋម. បាក់ទូក ភ្នំពេញ | 24.02.18 | មហារីកថ្លើម | 1436កព | 7231 |
| 34 | ប៉ុច ពុន | ៥២ | ប | យោធា | ស្វាមី អ្នកគ្រូ ជុំ សុជាត វិទ្យា. បាក់ទូក រភ្នំពេញ | 24.02.18 | មហារីកថ្លើម | 6929កព | 7232 |
| 35 | ជួន ជីវ័ន្ត | ៣៨ | ប | បឋម | ស្វាមី អ្នកគ្រូ ជ៉ត ចាន់ដាលីន វិទ្យា. បាក់ទូក ភ្នំពេញ | 15.02.18 | ជំងឺក្រលៀន | 10152កព | 7233 |
| 36 | ស៊ឹម ស៊ីធន | ៨២ | ប | ប្រជាជន | ស្វាមី អ្នកគ្រូ ឈាវ មួយហេង គរុកោសល្យ ភូមិភាគរាជធានីភ្នំពេញ | 19.01.18 | ជំងឺតម្រងនោម | 6017កព | 7234 |
| 37 | ថៃ វិទ្ធី | ៥៩ | ប | កសិករ | ប្តីអ្នកគ្រូ ចូ ចិន្តា បឋម. គំរូ ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ | 21.04.18 | ទឹកនោមផ្អែម | 2420បជ | 7235 |
| 38 | ហម សាមី | ៦៥ | ស | កសិករ | ប្រពន្ធលោកគ្រូ យិន សុភាព និ.បឋម.តាំងស្រី បាធាយ ខេត្តកំពង់ចាម | 03.04.18 | ជរាពាធ | 5302កច | 7236 |

មេត្តាប្រមូលភាគទានឧបត្ថម្ភប្រចាំខែ ឧសភាឆ្នាំ ២០១៨ឱ្យទាន់ពេលវេលាដើម្បីដោះស្រាយជូនគ្រួសារសព។

<u>ចំណាំ:</u> ត្រូវបង់ប្រាក់ឧបត្ថម្ភសពសមាជិក 65ន x 50៛ = 3250៛
ត្រូវបង់ប្រាក់ឧបត្ថម្ភសពគូស្រករ 38ន x 25៛ = 950៛
ភាគទានប្រចាំខែ......................................= 200៛
ភាគទានសាងសង់ផ្ទះគ្រូបង្រៀន...................= 300៛

សរុប = 4.700៛

រាជធានីភ្នំពេញថ្ងៃទី ០២ខែ ឧសភា ឆ្នាំ២០១៨
ជ. គណៈកម្មាធិការកណ្តាល
ប្រធាន

**លេខ: ១៨/១៨ គ.ក**

## សេចក្តីជូនដំណឹងមរណភាពប្រចាំខែ មិថុនា ឆ្នាំ២០១៨

| លរ | គោត្តនាម-នាម | អាយុ | ភេទ | ក្របខ័ណ្ឌ | អង្គភាពបម្រើការងារ | ថ្ងៃខែឆ្នាំមរណៈ | មូលហេតុ | លេខប័ណ្ណ | សពទី |
|---|---|---|---|---|---|---|---|---|---|
| | | | | | ក.មរណភាពសមាជិក | | | | |
| 1 | ភឹង ប៊ុនលី | 61 | ប | បឋម | បឋម.ចំការចេក ស្រុកមង្គលបុរី បន្ទាយមានជ័យ | 22.04.18 | ជរាពាធ | 943បជ | 12723 |
| 2 | ញូង ព្រីធា | 60 | ប | កម្មករ | និវត្តជន បឋម.ឆាត ស្រុក ខេត្ត បន្ទាយមានជ័យ | 03.05.18 | ជរាពាធ | 1585បជ | 12724 |
| 3 | ជុំ សារូ | 29 | ប | បឋម | បឋមសិក្សាកាំបាក់ ស្រុកកូនមុំ ខេត្តរតនគិរី | 14.09.17 | ជរាពាធ | 984រត | 12725 |
| 4 | សេន ចាន់រ័ត្ន | 39 | ស | បឋម | បឋម. ហ៊ុន សែនភូមិថ្មី ស្រុកបាលុង ខេត្តរតនគិរី | 17.11.17 | ជរាពាធ | 579រត | 12726 |
| 5 | អ៊ុំ ទិត្យ | 68 | ប | បឋម | និវត្តន៍ជន នៅមន្ទីរ អយក ខេត្តរតនគិរី | 29.12.17 | ជរាពាធ | 323រត | 12727 |
| 6 | កូវ ពៃ | 66 | ប | បឋម | និវត្តន៍ជន បឋមសិក្សា សង្គមមានជ័យ ស្រុកកូនមុំ | 23.01.18 | ជរាពាធ | 323រត | 12728 |
| 7 | មួង សំអាត | 71 | ប | បឋម | និវត្តជន បឋមផ្លូវបំបែក មោងឫស្សី ខេត្តបាត់ដំបង | 24.02.18 | លើសឈាម | 3975បប | 12729 |
| 8 | កោត សុភាព | 38 | ស | បឋម | បឋមកោះរាម ស្រុកបវេល ខេត្តបាត់ដំបង | 04.03.18 | ទាចទឹក | 7718បប | 12730 |
| 9 | សោម ផល្លី | 46 | ស | បឋម | វិទ្យាល័យព្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង | 07.03.18 | គាំងបេះដូង | 1541បប | 12731 |
| 10 | ថោង យិប | 83 | ប | បឋម | និវត្តជន បឋមសោមនស្សស្រុកឯកភ្នំ ខេត្តបាត់ដំបង | 12.03.18 | ជរាពាធ | 4312បប | 12732 |
| 11 | មៀច ចាន់លី | 61 | ស | បឋម | បឋមបាយដំរាំ ស្រុក បាណន់ ខេត្តបាត់ដំបង | 23.03.18 | ជរាពាធ | 3234បប | 12733 |
| 12 | ផ្លុង សារឿន | 88 | ប | មទក | និវត្តជន មន្ទីរអប់រំយុវជននិងកីឡា ខេត្តបាត់ដំបង | 23.04.18 | ជរាពាធ | 06បប | 12734 |
| 13 | ក្រូច ផុន | 60 | ស | បឋម | បឋមសិក្សាសែប ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង | 30.03.18 | ឡើងឈាម | 01130កឆ | 12735 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 14 | ម៉ុត សុភក្តិ | 36 | ស | បឋម | វិទ្យាល័យព្រះបាទសុរាម្រឹត ខេត្តកំពង់ឆ្នាំង | 03.04.18 | បេះដូងរីក | 03426កឆ | 12736 |
| 15 | ជា សារ៉ុន | 46 | ប | បឋម | បឋមសិក្សាសូរវង្ស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង | 13.04.18 | ជម្ងឺថ្លើម | 01102កឆ | 12737 |
| 16 | ស៊ុ ស៊ិន | 54 | ប | មធ្យម | វិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន រលាប្អៀរ ខេត្តកំពង់ឆ្នាំង | 08.02.18 | មហារីកថ្លើម | 02452កឆ | 12738 |
| 17 | កែវ សម្បត្តិ | 58 | ប | បឋម | បឋម.ក្រាំងល្វា ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង | 13.03.18 | ក្រពះពោះវៀន | 00705កឆ | 12739 |
| 18 | ឡឹក ពៅល | 71 | ប | បឋម | បឋមសិក្សា ត្រពាំងវែង ស្រុកគងពិសី ខេត្តកំពង់ស្ពឺ | 01.04.18 | ជរាពាធ | 424កស្ព | 12740 |
| 19 | សំរិត ថា | 56 | ប | បឋម | បឋមសិក្សា ត្រពាំងឈូក ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ | 19.04.18 | ជរាពាធ | 2240កស្ព | 12741 |
| 20 | ឈឹម សុជាតិ | 70 | ប | ម.កំ1 | វិទ្យាល័យ.ហ.ស.កំពង់ភ្នំ ស្រុកលើកដែក ខេត្តកណ្តាល | 12.03.18 | លើសឈាម | 1922កណ | 12742 |
| 21 | អឿន ណារ៉ុម | 56 | ស | បឋម | បឋម. ហ.ស.ព្រែកតូច ស្រុកលើកដែក ខេត្តកណ្តាល | 15.03.18 | ស្ទះពោះវៀន | 2103កណ | 12743 |
| 22 | ម៉ា លីម | 63 | ស | បឋម | បឋម. ត្រពាំងវែង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល | 30.03.18 | ជម្ងឺសួត | 4387កណ | 12744 |
